ខែធ្នូ ឆ្នាំ២០១០

# ចេញជាចំហនៅព្រះរាជាណាចក្រកម្ពុជា៖ ពលរដ្ឋខ្មែរដែលស្រលាញ់ភេទដូចគ្នា



មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
CAMBODIAN CENTER FOR HUMAN RIGHTS

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(ម.ស.ម.ក) គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនមាននិន្នាការនយោបាយដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សនៅកម្ពុជា។ ទស្សនៈវិស័យរបស់ ម.ស.ម.ក គឺកម្ពុជា គ្មានអំពើហិង្សា ដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសិទ្ធិស្មើគ្នា និងត្រូវបានផ្តល់អំណាចដើម្បីចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានការចែករំលែកផលប្រយោជន៍ពីការអភិវឌ្ឍប្រទេសនៅកម្ពុជា។ យើងចង់បាននីតិរដ្ឋជាជាងនិទណ្ឌភាព-ស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង- និងសង្គម សេរីពហុបក្សដែលភាពចម្រុះត្រូវបានគេ ស្វះស្វែងរក និងអបអរសាទរជាជាងការមិនអើពើ និងការដាក់ទោស។ ស្លាកសញ្ញារបស់យើងមានរូបព្រាបពណ៌សហោះហើរក្នុងរង្វង់ផ្ទៃមេឃពណ៌ខៀវ -បញ្ជាក់អំពីការទាមទារសេរីភាពនៅកម្ពុជា។

របាយការណ៍នេះ *ចេញជាចំហនៅព្រះរាជាណាចក្រកម្ពុជា៖ ពលរដ្ឋខ្មែរដែលស្រលាញ់ភេទដូចគ្នា* គឺជាលទ្ធផលនៃគម្រោងសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នាដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាកំពុងអនុវត្តន៍។

## សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះត្រូវបានចងក្រងឡើងដោយមានការជួយឧបត្ថម្ភពី Swedish Association for Sexuality Education (*Riksförbundet för sexuell upplysning*) ។ រាល់ខ្លឹមសារនៅក្នុងរបាយការណ៍នេះ គឺជាការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។

## ការសាកសួរបន្ថែម និងមតិយោបល់

ប្រសិនបើលោកអ្នកមានសំនួរ ឬចង់បានព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ ឬលោកអ្នកចង់ផ្តល់មតិកែលំអ សូមសរសេរអ៊ីម៉ែលមកកាន់www.cchrcambodia.org ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩
សង្កាត់បឹងត្របែក ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
អ៊ីម៉ែល៖ info@cchrcambodia.org
ទូរស័ព្ទ៖ +៨៥៥ ២៣ ៧២ ៦៩ ០១
ទូរសារ៖ +៨៥៥ ២៣ ៧២ ៦៩ ០២
វែបសាយ៖ http://www.cchrcambodia.org

# ចេញជាចំហនៅព្រះរាជាណាចក្រកម្ពុជា៖ ពលរដ្ឋខ្មែរដែលស្រលាញ់ភេទដូចគ្នា

របាយការណ៍នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

ខែធ្នូ ឆ្នាំ២០១០

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
CAMBODIAN CENTER FOR HUMAN RIGHTS

# មាតិកា


មាតិកា ......................................................................................... ៣

អក្សរកាត់ ..................................................................................... ៤

សេចក្តីសង្ខេប................................................................................ ៥

១. សេចក្តីផ្តើម ................................................................................ ៨

២. ការយល់ឃើញនៃទំនោរផ្លូវភេទ និងការកំនត់យេនឌ័រនៅកម្ពុជា................ ១២

ការយល់ឃើញផ្នែកវប្បធម៌ ..................................................................... ១២

ការយល់ឃើញផ្នែកសាសនា.................................................................. ១៥

ការទទួលស្គាល់ផ្នែកនយោបាយ ............................................................ ១៦

៣. ស្ថានភាពបច្ចុប្បន្ននៃអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជា ........................... ១៩

កង្វះខាតការយល់ដឹងនៅក្នុងគ្រួសារ និងសហគមន៍ ................................. ១៩

សំពាធផ្នែកសេដ្ឋកិច្ច និងការរើសអើងលើការងារ ..................................... ២១

ការរើសអើង និងការរំលោភបំពានពីរដ្ឋ ................................................ ២៣

៤. សិទ្ធិមនុស្ស និងសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា........................................ ២៤

ច្បាប់ជាតិ.......................................................................................... ២៦

ច្បាប់អន្តរជាតិ ................................................................................... ២៨

ដំណើរការវិវឌ្ឍន៍អន្តរជាតិដទៃទៀត...................................................... ៣០

៥. ចលនាអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជា............................................... ៣៣

៦. សន្និដ្ឋាន ..................................................................................... ៣៧

៧. ឯកសារយោង ................................................................................ ៣៩

# អក្សរកាត់

| | |
|---|---|
| "Cambodia" | ព្រះរាជាណាចក្រកម្ពុជា |
| "Constitution" | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា |
| "CCHR" | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| "ICCPR" | អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ |
| "ICESR" | អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ |
| "KHANA" | អង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនិងជំងឺអេដស៍ |
| "LGBT" | អ្នកស្រលញ់ភេទដូចគ្នា |
| "LGBT Project" | គម្រោងអ្នកស្រលាញ់ភេទដូចគ្នាដែលអនុវត្តដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| "LGBT Groups and individuals" | ក្រុម និង បុគ្គលអ្នកស្រលាញ់ភេទដូចគ្នាដទៃទៀត |
| "MSM" | បុរសស្រលាញ់បុរស |
| "RGC" | រាជរដ្ឋាភិបាលកម្ពុជា |
| "RoCK" | សហគមន៍ឥន្ទធនូកម្ពុជា |
| "UDHR" | សេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស |
| "Workshop" | សិក្ខាសិលាអ្នកស្រលាញ់ភេទដូចគ្នា រៀបចំឡើងដោយ RoCK និងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០១០ នៅរាជធានីភ្នំពេញ។ |
| "WSW" | ស្ត្រីស្រលាញ់ស្ត្រី |
| "Yogyakarta Principles" | គោលការណ៍យូកយ៉ាកាតាក្នុងការអនុវត្តច្បាប់សិទ្ធិអន្តរជាតិលើទំនោរផ្លូវភេទ និងការកំនត់យេនឌ័រ |

# សេចក្តីសង្ខេប

ដោយសារតែមានភាពខុសគ្នានៅក្នុងភាសា និងវប្បធម៌ ទស្សនៈនៃ 'ការស្រលាញ់ភេទដូចគ្នា' ដែលគេបានយល់ដឹងនៅប្រទេសលោកខាងលិចមិនអាចបកប្រែដោយផ្ទាល់ដើម្បីឲ្យគេអាចយល់បានទេនៅក្នុងបរិបទកម្ពុជា។ ផ្ទុយទៅវិញ ការយល់ដឹងនៅកម្ពុជាអំពីការរួមភេទកើតចេញមកពីទស្សនៈយែនឌ័រ អត្តចរិក និងលក្ខណៈបុគ្គល។ ការផ្តោតទៅលើអត្តចរិក និងលក្ខណៈបុគ្គលដែលត្រូវបានគេមើលឃើញយ៉ាងច្បាស់ជាជាងទំនោរផ្លូវភេទបានបង្ហាញថា ប្រជាជនកម្ពុជាភាគច្រើនដែលរួមភេទដូចគ្នាមិនបានកំនត់ពីអត្តសញ្ញាណរបស់ខ្លួនឯងទេ។

ក្នុងចំណោមអ្នកកាន់ពុទ្ធសាសនា គេមានអារម្មណ៍ជាទូទៅមួយក្នុងការសណ្តោសប្រណីដល់អ្នកស្រលាញ់ភេទដូចគ្នា។ ដោយសារតែវប្បធម៌នេះមានមនុស្សភាគច្រើនជាអ្នកកាន់ពុទ្ធសាសនា ការស្រលាញ់ភេទដូចគ្នា ដែលត្រូវបានគេមើលឃើញថាជារឿងចម្លែកមិនបានទាក់ទាញនូវការសកម្មភាពឆ្លើយតបហួសហេតុដូចអ្វីដែលគេបានមើលឃើញនៅក្នុងវប្បធម៌នៃអ្នកកាន់សាសនាគ្រឹស្ត ឬសាសនាឥស្លាមឡើយ។ ពុទ្ធសាសនាមិនបានផ្តល់តម្លៃទៅលើអាពាហ៍ពិពាហ៍ ឬការបង្កើតកូនឡើយ។ អាពាហ៍ពិពាហ៍ និងការបង្កើតកូនអាចត្រូវបានគេមើលឃើញថាជាភាពវិជ្ជមាន ប្រសិនបើបាននាំមកនូវក្តីស្រលាញ់ និងការគោរព ប៉ុន្តែអាចមានផលអវិជ្ជមាន ប្រសិនបើមានការឈឺចាប់ ឬបញ្ហា។ នៅកម្ពុជាសំពាធផ្នែកវប្បធម៌ សង្គម និងសេដ្ឋកិច្ចបានបដិសេធចោលនូវទ្រឹស្តីរបស់ពុទ្ធសាសនាអំពីអាពាហ៍ពិពាហ៍។ គេមិនបានភ្ជាប់ការពេបជ្រាយទៅនឹងមនុស្សដែលគ្មានកូន ឬមិនបានរៀបការឡើយ។

អតីតព្រះមហាក្សត្រនរោត្តម សីហនុបានសម្តែងការគាំទ្រជាសាធារណៈចំពោះអ្នកស្រលាញ់ភេទដូចគ្នា ក៏ប៉ុន្តែអ្នកនយោបាយវិញមានទស្សនៈខុសៗគ្នា។ នៅឆ្នាំ២០០៧ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានកាត់កាល់កូនស្រីរបស់គាត់ដោយសារតែជាស្ត្រីស្រលាញ់ស្ត្រីដូចគ្នា នៅខណៈពេលដែលសម្តេចបានអំពាវនាវឲ្យឪពុកម្តាយដែលមានកូនស្រលាញ់ភេទដូចគ្នាកុំមានការរើសអើងនឹងពួកគេ។ បញ្ហាប្រឈមដែលអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជាបានជួបប្រទះមិនត្រូវបានរាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ឡើយ និងហាក់ដូចជាមិនបានដាក់បញ្ហាទាំងអស់នោះទៅក្នុងរបៀបវារៈរបស់រាជរដ្ឋាភិបាលទាល់តែសោះ។

ការរួមភេទដូចគ្នាមិនខុសច្បាប់ទេនៅកម្ពុជា និងមិនមានទំនៀមទម្លាប់ក្នុងសាសនាប្រឆាំងនឹងអ្នកស្រលាញ់ភេទដូចគ្នាឡើយ។ ក៏ប៉ុន្តែ អ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជានៅតែប្រឈមនឹងការរើសអើង ឬការរំលោភបំពានពីសមាជិកគ្រួសារ និយោជក និងប៉ូលីស។

សង្គមកម្ពុជាអាចមានការសណ្ដោសប្រណីចំពោះសកម្មភាពរួមភេទដូចគ្នា ប្រសិនណាបើគ្មានការជាប់ទាក់ទង និងមិនបានប៉ះពាល់ដល់រចនាសម្ព័ន្ធប្រពៃណីគ្រួសារ។ អាកប្បកិរិយានៃការរួមភេទក្នុងចំណោមយុវជនអាចត្រូវបានគេមើលឃើញថាជាការសាកល្បងដោយមិនមានគ្រោះថ្នាក់ ដោយសារគេបានគិតថាស្ត្រីនៅតែមានភាពបរិសុទ្ធរហូតដល់ពេលរៀបការ។ គេអាចបំភ្លេចចោល ឬបន្តមិនយកចិត្តទុកដាក់លើការធ្វេសប្រហែសរបស់យុវជន។ ក៏ប៉ុន្តែ បុរសនឹងអាចរៀបការ និងក្លាយជាឪពុកកុមារ។ ដោយសារតែតួនាទីប្រពៃណីយែនឌ័រ ស្ត្រីមានលទ្ធភាពក្នុងការស្វែងរកទំនាក់ទំនងរវាងភេទដូចគ្នាតិចជាងបុរសដែលរួមភេទជាមួយបុរសទាំងជាលក្ខណៈឯកជន និងនៅកន្លែងសាធារណៈ។

ដោយសារតែគេបានផ្ដោតទៅលើអាពាហ៍ពិពាហ៍ និងការមានកូន អ្នកស្រលាញ់ភេទដូចគ្នាភាគច្រើននឹងទទួលរងសម្ពាធពីគ្រួសារដើម្បីបន្តវេនក្នុងគ្រួសារ។ ក្រៅពីនេះ កង្វះខាតនៃប្រព័ន្ធសុវត្ថិភាពសង្គមបានបង្ហាញថាអ្នកជំនាន់មុនបានទទួលបន្ទុកយ៉ាងធ្ងន់ធ្ងរក្នុងការគាំទ្រ និងថែទាំអ្នកជំនាន់ក្រោយនៃគ្រួសារ។ ការស្វែងរកទំនាក់ទំនងរវាងភេទដូចគ្នាគឺជាវិធីមួយដែលបុគ្គលភាគច្រើនមិនមានលទ្ធភាពផ្នែកសង្គម និងផ្នែកសេដ្ឋកិច្ចក្នុងការស្វែងរកបាន។ ភាពគ្រោះថ្នាក់នៃការផាត់ចេញពីសមាជិកគ្រួសារដែលជិតស្និត និងការលំបាកផ្នែកសេដ្ឋកិច្ច ដោយសារការរស់នៅក្រៅពីសមាជិកគ្រួសារអាចបញ្ជាក់ថាអ្នកស្រលាញ់ភេទដូចគ្នាមិនអាចរស់នៅបានតាមដែលពួកគេចង់បាន ឬចាំបាច់ត្រូវតែមានទំនាក់ទំនងផ្លូវភេទដូចគ្នាដោយសម្ងាត់។

នៅពេលដែលអ្នកស្រលាញ់ភេទដូចគ្នាហាក់ដូចជាបានប្រឈមមុខខ្លាំងនឹងការរំលោភបំពានពីគ្រួសារ និងសហគមន៍ខ្លួនឯង នៅពេលខ្លះពួកគេបានទទួលរងការឈឺចាប់ពីសង្គមជាតិតាមរយៈសកម្មភាពមួយចំនួនរបស់អាជ្ញាធរ។ អ្នកដែលមានសិទ្ធិអំណាចនៅក្នុងប្រទេសដែលជម្រុញ និងត្រួតពិនិត្យការរើសអើង ឬអំពើហិង្សាលើអ្នកស្រលាញ់ភេទដូចគ្នាបានស្រមៃឃើញទាំងដឹងខ្លួន និងមិនដឹងខ្លួនថាសកម្មភាពនេះជាទណ្ឌកម្មទៅលើអ្នកដែលមិនបានគោរពតាមទំនៀមទម្លាប់ ដែលគេបានទទួលយក។ ជនល្មើសតែងតែមានអារម្មណ៍ថាមានសិទ្ធិ ដោយមើលឃើញខ្លួនឯងថាមានឋានៈសង្គមខ្ពស់ជាង និងការគោរពផ្នែកសីលធម៌ខ្ពស់ជាងអ្នកស្រលាញ់ភេទដូចគ្នាដែលត្រូវបានគេចាត់ទុកថាមិនស្អាតបាតផ្នែកសីលធម៌ និងជាពលរដ្ឋលំដាប់ថ្នាក់ទីពីរ។

មនុស្សស្រលាញ់ភេទដូចគ្នាមានសិទ្ធិគ្រប់យ៉ាងដូចមនុស្សឯទៀតដែរ។ ច្បាប់កម្ពុជា និងច្បាប់អន្តរជាតិបានហាមឃាត់ការរើសអើងលើបុគ្គលទាំងអស់ ដោយសារផ្អែកលើបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនរបស់ពួកគេ និងធានាបានសិទ្ធិ និងសេរីភាពស្មើគ្នា និងការអនុវត្តច្បាប់ស្មើគ្នាលើបុគ្គលទាំងអស់។

គេឃើញមានដំណើរការវិវត្តន៍ជាវិជ្ជមាននៅកម្ពុជាដែលបញ្ជាក់ថាសហគមន៍អ្នកស្រលាញ់ភេទដូចគ្នាបានកកើតឡើង។ នៅឆ្នាំ២០០៣ សកម្មជនកម្ពុជា និងអន្តរជាតិបានចាប់ផ្តើម *កម្មវិធី 'មោទនភាព'* នៅភ្នំពេញដែលជាការប្រារព្ធឡើងប្រចាំឆ្នាំ និងការទទួលស្គាល់សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា ដោយមានសកម្មភាពដូចជា មហោស្រពភាពយន្ត សិល្បៈបង្ហាញ និងការប្រមូលផ្តុំលក្ខណៈសង្គម និងស្របពេលជាមួយទិវាអន្តរជាតិប្រឆាំងនឹងបុរសរួមភេទជាមួយបុរស។ នេះគឺជា*ព្រឹត្តិការណ៍មោទនភាពធំជាងគេ* នៅភ្នំពេញនៅឆ្នាំ២០០៩ ដោយមានអ្នកចូលរួមជាង៥០០នាក់។

បន្ទាប់ពីជោគជ័យនៃព្រឹត្តិការណ៍នេះ អ្នកសម្របសម្រួលកម្មវិធីបានសម្រេចបង្កើត RoCK ។ គោលបំណងនៃក្រុមនេះគឺគាំទ្រ ពង្រឹង និងពង្រីកសហគមន៍អ្នកស្រលាញ់ភេទដូចគ្នាដែលមានស្រាប់នៅកម្ពុជា និងលើកកម្ពស់ការយល់ដឹងអំពីបញ្ហា និងសិទ្ធិនៃអ្នកស្រលាញ់ភេទដូចគ្នា។ អង្គការនេះចែកចេញជាក្រុមការងារ៤គឺ អប់រំសហគមន៍ សិទ្ធិ និងការតស៊ូមតិសម្រាប់អ្នកស្រលាញ់ភេទដូចគ្នា ការគាំទ្រស្ត្រីស្រលាញ់ស្ត្រី និងគណកម្មការរៀបចំកម្មវិធីមោទនភាពឆ្នាំ២០១០។ ការបង្កើត RoCK បានបញ្ជាក់ពីការរីកលូតលាស់យ៉ាងច្បាស់លាស់សម្រាប់អ្នកស្រលាញ់ភេទនៅកម្ពុជា ដើម្បីចូលរួមយ៉ាងសកម្មក្នុងបុព្វហេតុសិទ្ធិមនុស្ស។

ប្រព័ន្ធអ៊ីនធើណេតបានជម្រុញឲ្យអ្នកស្រលាញ់ភេទកម្ពុជាភ្ជាប់ទំនាក់ទំនងជាមួយគ្នា ដើម្បីលើកកម្ពស់ការយល់ដឹងឲ្យបានទូលំទូលាយជាសកលនៅក្នុងសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា និងលទ្ធភាពនៃការចូលរួមផងដែរ។ ជីវិតសង្គមនៃអ្នកស្រលាញ់ភេទដូចគ្នាមានភាពល្អប្រសើរឡើងនៅរាជធានីភ្នំពេញ និងខេត្តសៀមរាប ជាអ្វីដែលត្រូវបានគេមើលឃើញថាសហគមន៍សង្គមដែលមានជិតស្និតសម្រាប់អ្នកស្រលាញ់ភេទដូចគ្នា។ នៅខណៈពេលដំណើរការវិវត្តន៍ដែលបានរៀបរាប់ខាងលើទទួលបានការលើកទឹកចិត្ត គេត្រូវកត់សម្គាល់ផងដែរថា ប្រជាជនកម្ពុជាភាគច្រើនដែលរស់នៅតំបន់ជនបទមិនបានដឹងពីដំណើរវិវត្តន៍នេះដែលបានកើតឡើងនៅភ្នំពេញឬតាមសហគមន៍លើប្រព័ន្ធអ៊ីនធើណែត។

គម្រោងសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នានៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាមានគោលបំណងធ្វើការផ្តល់អំណាចដល់អ្នកស្រលាញ់ភេទដូចគ្នាកម្ពុជាទាំងនៅតំបន់ទីក្រុង និងតំបន់ជនបទ តាមរយៈការផ្តល់នូវព័ត៌មាន និងការសម្របសម្រួលឲ្យក្រុម និងអ្នកស្រលាញ់ភេទដូចគ្នាអាចបង្កើតទំនាក់ទំនងមានប្រសិទ្ធភាព ព្រមទាំងផ្តល់នូវការបណ្តុះបណ្តាលដើម្បីចងក្រងឯកសារករណីរំលោភបំពានដែលបានកើតឡើងនៅទូទាំងប្រទេសកម្ពុជា។ គម្រោងអ្នកស្រលាញ់ភេទដូចគ្នានឹងគាំទ្រអ្នកស្រលាញ់ភេទដូចគ្នាកម្ពុជាលើសកម្មភាពតស៊ូមតិដើម្បីការទទួលស្គាល់លើការពិតដែលថាអ្នកស្រលាញ់ភេទដូចគ្នាមានសិទ្ធិដូចមនុស្សរាល់ៗគ្នាដែរ។

# ១. សេចក្តីផ្តើម

ប្រទេសមួយកំពុងជាសះស្បើយពីការជិះជាន់ និងការបំផ្លិចបំផ្លាញដោយសង្គ្រាមអស់រយៈពេលជាច្រើនឆ្នាំ និងសង្គមដែលបានប្រឈមមុខ និងការរំលោភបំពានសិទ្ធិមនុស្សនៅតំបន់ជាច្រើន បុគ្គលដែលជាបុរសស្រលាញ់បុរស ស្ត្រីស្រលាញ់ស្ត្រី អ្នកស្រលាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ(“អ្នកស្រលាញ់ភេទដូចគ្នា”)នៅក្នុងព្រះរាជាណាចក្រកម្ពុជា(ប្រទេសកម្ពុជា)ជួបប្រទះនូវការលំបាក ក្នុងការទទួលបានសិទ្ធិស្មើគ្នា។ ខណៈពេលដែលអ្នកស្រលាញ់ភេទផ្ទុយគ្នាស្របច្បាប់នៅកម្ពុជា បុគ្គលដែលជាអ្នកស្រលាញ់ភេទដូចគ្នាមិនត្រូវបានគេយកចិត្តទុកដាក់ទាំងនយោបាយ និងសង្គម។

បុគ្គលស្រលាញ់ភេទដូចគ្នា(អ្នកស្រលាញ់ភេទដូចគ្នា)នៅកម្ពុជាប្រឈមមុខនិងការរើសអើង និងការរំលោភបំពានពីក្រុមគ្រួសារ សហគមន៍ និងនិយោជកប៉ុណ្ណោះទេ គឺថែមទាំងទទួលរងពីស្ថាប័នរដ្ឋដូចជាអាជ្ញាធរមូលដ្ឋាន និងប៉ូលីសជាដើម។ ទោះបីជាការឈ្លក់វង្វេងនឹងសាសនា និងការបៀតបៀនផ្លូវភេទជារឿងធម្មតា ឧបទ្ទវហេតុរបស់បុគ្គលម្នាក់ៗមិនត្រូវបានកត់ត្រាទុក ដោយមិនបញ្ជាក់ពីភាពលំអៀងដែលទាក់ទងនិងអត្តសញ្ញាណរបស់អ្នកស្រលាញ់ភេទដូចគ្នា ដែលបណ្តាលមកពីខ្វះខាតការទទួលស្គាល់ និងការគាំទ្រក្នុងការឆ្លើយតបទៅនិងការរើងអើងបែបនោះ។ ដូច្នេះ បុគ្គលដែលស្រលាញ់ភេទដូចគ្នាជារឿយៗ នឹងមិនរាយការណ៍ពីតួយ៉ាងនៃការរើសអើង និងការរំលោភបំពាន ដោយគ្មានសំណងនោះទេ។ អ្នកដែលធ្វើរបាយការណ៍នៃការរំលោភបំពាននោះអាចព្រងើយកន្តើយ ឬធ្វើឲ្យកាន់តែអាក្រក់ឡើង ឬការរំលោភបំពានបន្ថែម។ ជាលទ្ធផល បុគ្គលដែលជាអ្នកស្រលាញ់ភេទដូចគ្នានៅប្រទេសកម្ពុជាជារឿយៗមិនបានដឹងនូវកន្លែងដោះស្រាយ ពេលដែលទទួលរងភាពអយុត្តិធម៌។

កត្តាមួយសំខាន់ៗដែលជាប់ទាក់ទងនិងការរើសអើងប្រឆាំង និងបុគ្គលស្រលាញ់ភេទដូចគ្នាគឺការសង្កត់ធ្ងន់ទៅលើប្រពៃណីគ្រួសាររបស់សង្គមកម្ពុជា។ បុគ្គលគ្រប់រូប និងទំនាក់ទំនងដែលប្រព្រឹត្តខុសបទដ្ឋានបានទទួលរងការពេបជ្រាយ។ សំពោធវប្បធម៌ សង្គម នយោបាយ និងសេដ្ឋកិច្ចបានបញ្ជាក់ថាបុគ្គលគ្រប់រូបគួររៀបការជាមួយមនុស្សដែលមានភេទផ្ទុយគ្នា និងបង្កើតកូន។ បុគ្គលខ្លះទៀតថែមទាំងបដិសេធចោលនូវបុគ្គលដែលស្រលាញ់ភេទដូចគ្នាដែលមាននៅក្នុងប្រទេសកម្ពុជាទៀតផង។

ដោយសារការពេបជ្រាយទៅលើអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជា និងការនៅតែស្ទាក់ស្ទើរក្នុងការនិយាយពីបញ្ហានៃការរើសអើង គេមានការយល់ដឹងតិចតួចពីបទពិសោធន៍បុគ្គលដែលស្រលាញ់ភេទ

ដូចគ្នានៅក្នុងគ្រួសារ និងសហគមន៍របស់ពួកគេ។ បញ្ហានេះបានជម្រុញឲ្យមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាធ្វើការវាយតម្លៃពីស្ថានភាពនៅពេលថ្មីៗនេះ។ តាមរយៈការនិយាយជាមួយបុគ្គលស្រលាញ់ភេទដូចគ្នាកំពុងរស់នៅតាមសហគមន៍ គម្រោងសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នានៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានរកឃើញថាមានសញ្ញាមួយចំនួននៃការកើតឡើងនៃសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា។ គម្រោងនេះនឹងផ្តល់អំណាចដល់សហគមន៍ក្នុងការលើកកម្ពស់សិទ្ធិនៃអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជា។

ខណៈពេលដែលរបាយការណ៍នេះប្រើប្រាស់បច្ចេកស័ព្ទរបស់អ្នកស្រលាញ់ភេទដូចគ្នា ដើម្បីពិភាក្សាពីស្ថានភាពរបស់ប្រជាជនដែលស្រឡាញ់ភេទដូចគ្នានៅកម្ពុជា វាមានសារៈសំខាន់ណាស់ក្នុងការចងចាំថាពាក្យបច្ចេកទេសទាំងនោះថ្មីចំពោះសង្គមកម្ពុជា រួមទាំងបុគ្គលស្រលាញ់ភេទដូចគ្នាផ្ទាល់ដែលមិនអាចបញ្ជាក់ពីអត្តសញ្ញាណខ្លួនឯងថាជា ស្ត្រីស្រលាញ់ស្ត្រី បុរសស្រលាញ់បុរស អ្នកស្រលាញ់ភេទទាំងពីរ ឬអ្នកប្តូរភេទ (ដូចបានពិភាក្សានៅក្នុងផ្នែកទី២នៃរបាយការណ៍នេះ)។ បញ្ញត្តិនៃទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ ដែលបានកើតមាននៅប្រទេសអឺរ៉ុបអាចមិនត្រឹមត្រូវក្នុងការសម្របសម្រួលមធ្យោបាយផ្លូវភេទ ដែលយគេយល់ដឹងនៅកម្ពុជាទេ។ ដូច្នេះ បញ្ហាប្រឈមមួយទៀតចំពោះសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជាគឺការស្វែងរកនូវភាសាដ៏សមស្របមួយ ដើម្បីប្រើនៅពេលមានការប្រជុំពិភាក្សាជាមួយប្រជាពលរដ្ឋកម្ពុជាអំពីបញ្ហានៃទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ។

នេះជាពេលវេលារដ៏សំខាន់សម្រាប់អភិវឌ្ឍន៍ចលនាអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជា។ របាយការណ៍នេះនឹងជាការចងក្រងឯកសារ និងការបង្ហាញពីស្ថានភាពថ្មីៗសំរាប់ប្រជាជនដែលស្រឡាញ់ភេទដូចគ្នាប៉ុណ្ណោះទេ តែក៏ជាការលើកកម្ពស់នូវការទទួលស្គាល់ពីសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា និងត្រួសត្រាយផ្លូវសម្រាប់ការពិភាក្សា និងការអប់រំអំពីសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នាដែលជាប់ទាក់ទងនិងបញ្ហានេះ។

## គោលបំណង បរិបទ និងវិធីសាស្រ្តនៃការរៀបចំរបាយការណ៍នេះ

មកទល់សព្វថ្ងៃនេះ គេបានធ្វើការសិក្សាតិចតួចអំពីស្ថានភាពអ្នកស្រលញ់ភេទដូចគ្នានៅកម្ពុជា។ ការសិក្សាភាគច្រើនផ្តោតទៅលើបញ្ហាសុខភាពដែលទាក់ទងទៅនឹងសកម្មភាពផ្លូវភេទ។[1] របាយការណ៍

[1]ជាឧទាហរណ៍ សូមមើល តេអូដូរ អាំប្រូស៊ីអូ ខាតាឡា. ខា សុវណ្ណារ៉ា និង ជីវ៉ាត វាន់ មូរីក *ចេញពីស្រមោល៖ អាកប្បកិរិយារួមភេទពីបុរសទៅស្ត្រីនៅកម្ពុជា* (ភ្នំពេញ៖ អង្គការខាណា/សម្ព័ន្ធអង្គការអន្តរជាតិប្រឆាំងនឹងជម្ងឺអេដស៍ ២០០៣)។ ខា សុវណ្ណារ៉ា និង គ្រីស វ៉ត *បុរសដែលរួមភេទជាមួយបុរសនៅកម្ពុជា៖ ភាពងាយរងគ្រោះនៃជម្ងឺអេដស៍ ការពេបជ្រាយ និងការរើសអើង* (ភ្នំពេញ គោល នយោបាយ/ USAID ២០០៤)។ មីឆេ រូដូហ និងសារ៉ា ហាស៊ី *អាកប្បកិរិយារួមភេទភេទ ជម្ងឺកាមរោគ និងមេរោគអេដស៍ក្នុងចំណោមបុរសដែលរួមភេទជាមួយបុរសនៅភ្នំពេញ កម្ពុជា ២០០០* (ភ្នំពេញ៖ អង្គការសុខភាពគ្រួសារអន្តរជាតិ/ USAID ២០០២)។

នេះនឹងបង្ហាញពីស្ថានភាពបច្ចុប្បន្ននៃអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជា ដោយឈរលើទស្សនៈសិទ្ធិមនុស្សដែលបានកត់សម្គាល់ថាអ្នកស្រលាញ់ភេទដូចគ្នាមានសិទ្ធិដូចគ្នានឹងអ្នកឯទៀតដែរនៅក្នុងសហគមន៍ ។

ផ្នែកទី២នៃរបាយការណ៍នេះបង្ហាញនូវទិដ្ឋភាពមួយចំនួននៃស្ថានភាពអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជាតាមរយៈការពិនិត្យមើលការយល់ឃើញនៅក្នុងបរិបទសង្គម និងសាសនាទៅលើអ្នកស្រលាញ់ភេទដូចគ្នា និងវិសាលភាពដែលអ្នកនយោបាយបានទទួលស្គាល់ពីការព្រួយបារម្ភរបស់សហគមន៍នៃអ្នកស្រលាញ់ភេទដូចគ្នា។ តាមរយៈបទសម្ភាសន៍ និងការពិភាក្សាជាមួយអ្នកស្រលាញ់ភេទដូចគ្នាកម្ពុជានៅទូទាំងប្រទេស ផ្នែកទី៣នឹងពិព័រណ៌នាអំពីបទពិសោធន៍ និងបញ្ហាប្រឈមដែលអ្នកស្រលាញ់ភេទដូចគ្នាកម្ពុជាបានជួប្រទះ។ ផ្នែកទី៤នឹងបង្ហាញអំពីទស្សនៈនៃការគោរពសិទ្ធិមនុស្សដោយបញ្ជាក់អះអាងថា អ្នកស្រលាញ់ភេទដូចគ្នាកម្ពុជាមានសិទ្ធិគ្រប់យ៉ាងដូចមនុស្សទាំងអស់នៅកម្ពុជា។ ការរើសអើងលើការទទួលស្គាល់ពីសិទ្ធិទាំងនេះត្រូវបានច្បាប់ជាតិ និងច្បាប់អន្តរជាតិហាមឃាត់។ ផ្នែកទី៥ធ្វើការសិក្សាអំពីការលេចចេញជារូបរាងឡើងនៃសហគមន៍អ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជាដែលកំពុងតែមានការរីកច្រើន និងឱកាសនៃការបង្កើតឡើងនូវចលនាអ្នកស្រលាញ់ភេទដូចគ្នាកម្ពុជាមួយ ដើម្បីជម្រុញឲ្យមានការទទួលស្គាល់ និងការគោរពសិទ្ធិស្មើគ្នានៃអ្នកស្រលាញ់ភេទដូចគ្នា។

ការស្រាវជ្រាវនៅក្នុងរបាយការណ៍នេះធ្វើឡើងតាមរយៈបទសម្ភាសន៍ជាមួយអ្នកស្រលាញ់ភេទដូចគ្នាកម្ពុជាប្រហែល៦០នាក់ កាលពីខែកញ្ញា និងខែតុលា ឆ្នាំ២០១០។ បទសម្ភាសន៍បានធ្វើឡើងនៅរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ធំ សៀមរាប បាត់ដំបង បន្ទាយមានជ័យ ពោធិសាត់ កំពង់ឆ្នាំង កំពង់ស្ពឺ តាកែវ និងព្រះសីហនុ។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានជួបជាមួយអ្នកផ្តល់បទសម្ភាសន៍ជាក្រុម និងលក្ខណៈឯកជន។ របៀបនៃការសម្ភាសន៍មិនមានលក្ខណៈផ្លូវការឡើយ។

សារសំខាន់ៗដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបាន ទទួលគឺថាអ្នកស្រលាញ់ភេទដូចគ្នាកំពុងទាមទារ៣ចំនុចគឺ (១) ការបញ្ឈប់ការរើសអើងនឹងពួកគេនៅក្នុងគ្រួសារ សាលារៀន និងសហគមន៍ (២) មានលទ្ធភាពក្នុងការរស់នៅជាមួយអ្នកដែលខ្លួនស្រលាញ់ និងមានគ្រួសារ និង(៣)មានការងារធ្វើដោយគ្មានការរើសអើង។

របាយការណ៍នេះគឺជាលទ្ធផលនៃគម្រោងសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នានៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាសម្រាប់រយៈពេលបីឆ្នាំដែលនឹងផ្តោតលើការធ្វើផែនទីនៃស្ថាប័នដែលធ្វើការជាមួយអ្នកស្រលាញ់ភេទដូចគ្នា និងនាំឲ្យក្រុមអ្នកស្រលាញ់ភេទដូចគ្នាដែលមានស្រាប់ អង្គការមិនមែនរដ្ឋាភិបាល ការផ្តួចផ្តើមនៅតាមសហគមន៍ អង្គការមហាជន ព្រមទាំងក្រុម និងបុគ្គលអ្នកស្រលាញ់ភេទដូចគ្នាបានជួបគ្នា។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាមានគោលបំណងផ្តល់អំណាចដល់ក្រុម និងបុគ្គលស្រលាញ់ភេទដូចគ្នាដើម្បីចងក្រងឯកសារ និងធ្វើការរាយការណ៍ពីការរំលោភបំពាន និងការរើសអើងលើអ្នកស្រលាញ់

ភេទដូចគ្នាព្រមទាំងគាំទ្រចលនាអ្នកស្រលាញ់ភេទដូចគ្នា តាមរយៈការស្រាវជ្រាវបន្ថែមទៀតអំពីបញ្ហា ដែលអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជាបានជួបប្រទះ។

# ២. ការយល់ឃើញនៃទំនោរផ្លូវភេទ និងការកំនត់យែនឌ័រនៅកម្ពុជា

អាកប្បកិរិយាចំពោះសេចក្តីស្នេហា និងការរួមភេទរវាងភេទដូចគ្នាខុសប្លែកគ្នាទៅតាមវប្បធម៌ និងក្នុងប្រវត្តិសាស្រ្តមនុស្ស។ ក៏ប៉ុន្តែ ដោយមិនគិតអំពីភាពខុសគ្នាផ្នែកវប្បធម៌នៃអាកប្បកិរិយា សេចក្តីស្នេហារវាងភេទដូចគ្នា និងសកម្មភាពរួមភេទដូចគ្នាបានកើតឡើងនៅក្នុងសង្គមជាច្រើន។ វប្បធម៌ទាំងអស់មានគុណតម្លៃរៀងៗខ្លួនៗ ទាក់ទននឹងទំនាក់ទំនងសមស្រប និងមិនសមស្រប និងការប្រព្រឹត្តផ្លូវភេទ។ អាកប្បកិរិយា និងការយល់ឃើញដែលបានឡើងនៅក្នុងវប្បធម៌នីមួយៗបានកំនត់ថាតើសកម្មភាពមួយណាអាចត្រូវបានទទួលយក ទទួលរងការពេបជ្រាយ ឬក៏ត្រូវបានដាក់ពិន័យ។ ផ្នែកនេះពិនិត្យមើលអំពីការយល់ឃើញនៃការកំនត់យែនឌ័រ និងទំនោរផ្លូវភេទនៅកម្ពុជា។

## ការយល់ឃើញផ្នែកវប្បធម៌

ដោយសារតែភាសា និងវប្បធម៌ខុសពីគ្នា បញ្ញត្តិនៃការស្រលាញ់ភេទដូចគ្នាដែលបានយល់នៅប្រទេសអឺរ៉ុបមិនចាំបាច់ត្រូវបកប្រែ ឬយល់ដឹងដោយផ្ទាល់នៅក្នុងបរិបទនៃប្រទេសកម្ពុជាទេ។ ភាសាខ្មែរមិនមានវាក្យស័ព្ទសម្រាប់ពិពណ៌នាឲ្យពិតប្រាកដពីការស្រលាញ់នៃភេទ និងអាកប្បកិរិយាផ្លូវភេទឡើយ។ នេះមានន័យថា គ្មានពាក្យសម្រាប់ពិពណ៌នាអំពីមនុស្សស្រលាញ់ភេទផ្ទុយគ្នា ស្រលាញ់ភេទដូចគ្នា និងស្រលាញ់ភេទទាំងពីរឡើយ។ ប្រជាជនកម្ពុជាមិនមានទំនៀមទម្លាប់បែងចែកមនុស្សតាមរបៀបនេះទេ។

ផ្ទុយទៅវិញ ប្រជាជនកម្ពុជាយល់ដឹងពីភេទ គឺបណ្តាលមកពីបញ្ញត្តិនៃយែនឌ័រ អត្តចរិក និងបុគ្គលិកលក្ខណៈនៅក្នុងករណីនៅអាស៊ីអាគ្នេយ៍ដែលប្រជាជនកម្ពុជាយល់ដឹងពីបញ្ញត្តិនៃយែនឌ័រ និងភេទមានលក្ខណៈតឹងរឹងតិចតួចជាងការបែងចែកផ្នែកប្រុស ឬ ស្រី[2] នៅប្រទេសអឺរ៉ុប។ យែនឌ័រត្រូវបានពិព័រណ៌នាជាម្មតាដោយប្រើពាក្យ "ស្រី និង "ប្រុស" ដែលមានន័យថា "មនុស្សភេទស្រី" និង "មនុស្សភេទប្រុស"។ ពាក្យថាញី និងឈ្មោល ក៏បានចង្អុលប្រាប់ពីយែនឌ័រដែលមានន័យថា "ប្រុស" និង "ស្រី"

[2] បាបារា អឺស *យែនឌ័រចំរុះ៖ អត្តសញ្ញាណភេទទីបីពីប្រុសទៅស្រី និងកម្មវិធីអេដស៍នៅកម្ពុជា យែនឌ័រ និងការអភិវឌ្ឍ វ៉ុល ១៤ លេខ ២ ខែកក្កដា ២០០៦ ទំព័រទី ២៦០។*

ផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ខណៈពេលដែលគូនៃពាក្យនេះត្រូវបានប្រើដើម្បីកំនត់ពីផ្នែកជីវសាស្ត្ររបស់មនុស្ស នៅក្នុងបរិបទខ្លះ ពាក្យទាំងអស់នោះត្រូវបានប្រើចំពោះសត្វ និងរុក្ខជាតិជាង។[3]

ពាក្យទី៥ គឺ *ខ្ទើយ* ដែលប្រើសម្រាប់ពិព័រណ៌នាអំពីយែននឌ័រផងដែរ តែមានការបកស្រាយផ្សេងពីគ្នា។ វាត្រូវបានកំនត់នៅក្នុងវចនានុក្រមវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យថា គឺជាមនុស្សដែលមានប្រដាប់បន្តពូជជាប្រុសផង និងស្រីផង។[4] ទោះជាយ៉ាងណាក៏ដោយ វាត្រូវគេបានប្រើជាធម្មតាដើម្បីពិព័រណ៌នាអំពីអ្នកទាំងឡាយណាដែលមានផ្នែកជីវសាស្ត្រជាមនុស្សប្រុស ឬមនុស្សស្រីធម្មតា ប៉ុន្តែបែរជាបង្ហាញពីបុគ្គលិកលក្ខណៈផ្ទុយពីភេទរបស់ខ្លួន។ តាមការឆ្លុះបញ្ចាំងពីការបកស្រាយខាងលើ ពាក្យ *ខ្ទើយ* ជារឿយៗត្រូវបានប្រើដើម្បីពិព័រណ៌នាពីមនុស្សប្រុសដែលស្លៀកពាក់ជាស្រី។[5]

នៅពេលដែលប្រជាជនកម្ពុជាមិនបានបែងចែកមនុស្សទូទៅដោយផ្អែកលើការស្រលាញ់នៃភេទ និងអាកប្បកិរិយាផ្លូវភេទមានភាពខុសប្លែកផ្សេងៗគ្នាដើម្បីជួយពន្យល់ពីភេទ។ សង្គមកម្ពុជាកត់សំគាល់ពីភាពខុសប្លែកគ្នាពីរនៃប្រភេទបុគ្គលិកលក្ខណៈ ឬចរិតសម្រាប់បុរស។ ចរិកមនុស្សស្ត្រីត្រូវបានស្គាល់ថាជាទន់ភ្លន់ ត្រូវបាននិយាយថាដើម្បីធ្វើឲ្យបុគ្គលិកលក្ខណៈដូចទៅនិងស្ត្រី។ ចំណែកឯចរិកមនុស្សប្រុស ឬប្រភេទចរិកលក្ខណៈរឹងមាំបានបង្ហាញពីអ្វីដែលត្រូវបានគេចាត់ទុកថាមានលក្ខណៈប្រពៃណីជាបុគ្គលិកលក្ខណៈជាបុរសច្រើនជាង។[6]

ការផ្តោតលើលក្ខណៈអត្តចរិកទាំងនេះ និងអាកប្បកិរិយាដែលមើលឃើញពីខាងក្រៅជំនួសឲ្យទំនោរផ្លូវភេទ នោះមានន័យថាប្រជាជនកម្ពុជាជាច្រើនដែលជាអ្នកស្រលាញ់ភេទដូចគ្នាមិនបង្ហាញថាខ្លួនរបស់ពួកគេថាអញ្ចឹងទេ។ សូម្បីតែនៅពេលដែលប្រជាជនកម្ពុជាប្រើពាក្យថា "ខ្ទើយ" ពួកគេជាទូទៅសំដៅទៅលើបុរសដែលមើលពីខាងក្រៅទៅជាស្ត្រី ឬក្នុងចំនួនតិចតួចណាស់សំដៅលើស្ត្រីដែលមើលពីខាងក្រៅទៅជាបុរស។ ដូច្នេះ បុគ្គលគ្រប់រូបអាចពិព័រណ៌នាខ្លួនរបស់ពួកគេថាជា "អ្នកស្រលាញ់ភេទផ្ទុយគ្នា" ដែលផ្ទុយពីសកម្មភាពនៃការស្រលាញ់ផ្អែកភេទដូចគ្នារបស់ពួកគេ។ ដូចដែលប្រជាជនកម្ពុជា

---

[3] ផុង តាន *កម្មវិធីបង្ការជំងឺអេដស៍៖ ការសិក្សាអំពីការួមភេទរវាងបុរសទៅបុរសនៅកម្ពុជា* (ភ្នំពេញ អង្គការ UNESCO ឆ្នាំ២០០៨) ទំព័រទី២១ ។ អាចរកបាននៅ http://unesdoc.unesco.org/images/0016/001630/163077E.pdf ។

[4] ដូចខាងលើ។

[5] ផុង តាន ទំព័រទី២២។

[6] ផុង តាន ទំព័រទី២២-២៦។

ម្នាក់បានអះអាងថា "ខ្ញុំមិនមែនជាខ្ទើយទេ។ ខ្ញុំគ្រាន់តែចូលចិត្តរួមភេទជាមួយបុរស។"[7] ហេតុនេះ សកម្មជន និងអ្នកស្រាវជ្រាវបានប្រើពាក្យថា "ស្ត្រីស្រលាញ់ស្ត្រី" (WSW) និង "បុរសស្រលាញ់បុរស" (MSM) ដើម្បីពិព័រណ៌នាពីស្ត្រី និងបុរសដែលស្រលាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជាយើង។[8] ទោះជាយ៉ាងណាក៏ដោយ ក៏បច្ចេកស័ព្ទនៅតែមានបញ្ហាដូចមានការពិភាក្សាខាងក្រោម។

ក្រុមនៃពាក្យបច្ចេកទេសផ្សេងទៀតប្រើដើម្បីបែងចែកបុគ្គលិកលក្ខណៈ និងអត្តចរិករបស់ បុរសស្រលាញ់បុរស។ អត្ថបទរបស់លោក បាបារា អឺស នៅក្នុងទនានុប្បវត្តិ ដែលមានចំណងជើងថា *យេនឌ័រ និងការអភិវឌ្ឍ* បានពិព័រណ៌នាអំពី "សក់ខ្លី" "សក់វែង" (ស្រីស្រស់ ឬស្រីមានមន្តស្នេហ៍) និង "បុរសពិត (មនុស្ស ពិតប្រាកដ ឬមនុស្សភេទប្រុស)។[9] ពាក្យ*សក់ខ្លី* និង*ប្រុសស្អាត* (ប្រុសសង្ហារ) ត្រូវបានប្រើនៅពេលខ្លះ ដើម្បីបែងចែកបុរសដែលស្លៀកពាក់ និងបង្ហាញថាជាបុរស ប៉ុន្តែអាចរួមភេទជាមួយបុរសនិងជាមួយស្ត្រី។ ខណៈពេលដែលពួកគេអាចបង្ហាញរូបរាងជាស្ត្រីដែលខុសពីច្បាប់ទម្លាប់សង្គម អត្តចរិកខាងក្រៅរបស់ពួកគេធ្វើឲ្យពួកគេធ្វើការបញ្ជ្រាបខ្លួនទៅក្នុងសង្គម។ អ្នកសក់ខ្លីមួយចំនួនតូចរួមភេទតែជាមួយបុរសតែប៉ុណ្ណោះ។[10] ជាធម្មតា ពួកគេរៀបការ ហើយប្រពន្ធរបស់ពួកគេមិនដឹងថាពួកគេអាចរួមភេទជាមួយមនុស្សដែលមានភេទដូចគ្នាបានទេ។[11] ចំណែកឯអ្នកមួយចំនួនដែលស្លៀកពាក់ជា*ស្រីស្រស់* (ស្រីមានមន្តស្នេហ៍) ក្នុងការចូលរួមពិធីផ្សេងៗ ជាធម្មតាពួកគេមិនស្លៀកពាក់ផ្ទុយពីភេទរបស់ពួកគេទេនៅតាមទីសាធារណៈ។ "អ្នកសក់ខ្លី" ខ្លះអាចមានកត្តាចិត្តសាស្ត្រជា "អ្នកសក់វែង" ប៉ុន្តែត្រូវកាត់សក់ ខ្លីដើម្បីឲ្យសង្គមទទួលស្គាល់ពួកគេ។[12]

*ស្រីស្រស់* រឺ"សក់វែង" ជាអ្នកប្តូរភេទដែលពាក់សក់វែង ហើយបង្ហាញការស្លៀកពាក់ និងសកម្មភាពជាស្ត្រី។ ពួកគេអាចចាក់អរម៉ូនដើម្បីផ្លាស់ប្តូររូបរាងរបស់ពួកគេ ឬបើសិនជាពួកគេមានប្រាក់ ពួកគេអាចវះកាត់ប្តូរភេទបាន។ នៅពេលដែលពួកគេអាចចាត់ទុកខ្លួនពួកគេថាជា "ខ្ទើយ" ពួកគេអាចនឹងរងការប្រមាថ ឬការរើសអើងដោយការហៅពួកគេថាជា "ខ្ទើយ" ជាជាងហៅថា*ស្រីស្រស់* ពីអ្នកដទៃ។[13]

---

[7] Integrated Regional Information Network (IRIN), *កម្ពុជា៖ ផ្តោតលើបុរសរួមភេទជាមួយបុរសដូចគ្នា និងការរីករាលដាលនៃជំងឺអេដស៍* ចេញផ្សាយថ្ងៃទី៣ មករា ២០០៧។ លោកអ្នកអាចរកបាននៅ http://www.irinnews.org/Report.aspx?ReportId=62964។

[8] MSM សំដៅទៅលើបុរសដែលបានចូលរួមសកម្មភាពរួមភេទជាមួយបុរសដូចគ្នា តែមិនមិនចាំបាច់ហៅពួកគេថារួមភេទដូចគ្នាឡើយ។

[9] បាបារា អឺស ទំព័រទី២៦១–២៦៣។

[10] បាបារា អឺស ទំព័រទី២៦១។

[11] ដូចខាងលើ។

[12] ដូចខាងលើ។

[13] បាបារា អឺស ទំព័រទី២៦២។

តាមលក្ខណៈចិត្តសាស្ត្រ ពួកគេបានចាត់ទុកខ្លួនពួកគេថាជាស្ត្រី ហើយចង់រួមរស់ជាមួយ"បុរសពិត"។[14] ដោយសារតែមូលហេតុនេះ ទើបពាក្យ MSM មិនត្រឹមត្រូវទេនៅពេលប្រើប្រាស់ចំពោះ*ស្រីស្រស់។*

គេគួរតែត្រូវគេសង្កត់ធ្ងន់ថា ខណៈពេលដែលភាសានិងបច្ចេកស័ព្ទជួយពន្យល់នូវរបៀប ដែលបញ្ញាត្តិយែនឌ័រ និងភេទ ត្រូវបានយល់នៅប្រទេសកម្ពុជា បុគ្គលិកលក្ខណៈ និងសេចក្តីស្រលាញ់របស់បុគ្គលម្នាក់ៗមានលក្ខណៈតែមួយឬអាចមិនមានភាពចាំបាច់ដើម្បីធ្វើការបែងចែកប្រភេទនោះទេ។

## ការយល់ឃើញផ្នែកសាសនា

នៅឆ្នាំ២០០៤ អតីតព្រះមហាក្សត្រនរោត្តម សីហនុបានលើកឡើងអំពីទស្សនៈរបស់ព្រះពុទ្ធទៅនឹងការរួមភេទថា "បុរសស្រលាញ់បុរស និងស្ត្រីស្រលាញ់ស្ត្រីនឹងមិនកើតមានទេ ប្រសិនបើព្រះមិនបានបង្កើតពួកគេ។ ក្នុងនាមជាអ្នកកាន់ពុទ្ធសាសនា ខ្ញុំត្រូវមានមេត្តាធម៌ចំពោះមនុស្សទាំងឡាយណាដែលមិនដូចខ្ញុំ លើកលែងតែអ្នកដែលមិនធ្វើបាបអ្នកដទៃ និងមិនសម្លាប់អ្នកណាម្នាក់។”[15]

ក្នុងចំណោមអ្នកកាន់ពុទ្ធសាសនា គេមានអារម្មណ៍ជាទូទៅមួយក្នុងការសណ្តោសប្រណីដល់ការស្រលាញ់ភេទដូចគ្នា។ ពាក្យទូន្មានសំខាន់ៗនៃព្រះពុទ្ធសាសនាធានាថាសកម្មភាពរបស់អ្នកកាន់ពុទ្ធសាសនា គឺគ្មានការឈឺចាប់ មានប្រយោជន៍ និងថាពួកគេទាំងអស់គ្នាជម្រុញការធ្វើអំពើល្អ។ នៅពេលដែលការស្រលាញ់ភេទដូចគ្នាអាចត្រូវគេមើលឃើញដូចគ្នានឹង “ បាបកម្ម ” ឥទ្ធិពលដែលជ្រួតជ្រាបនៃព្រះពុទ្ធសាសនាបានធ្វើឲ្យប្រជាជនកម្ពុជាប្រកាន់យកទ្រឹស្តី “រស់នៅ និងឲ្យរស់នៅ” ឬ “មិនសួរមិនប្រាប់” ទាក់ទងនឹងទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ។ ដោយសារតែក្នុងវប្បធម៌នេះ មនុស្សភាគច្រើនជាអ្នកកាន់ពុទ្ធសាសនាការស្រលាញ់ភេទដូចគ្នាដែលត្រូវបានគេមើលឃើញថាជារឿងចម្លែកដែលមិនបានទាក់ទាញនូវសកម្មភាពឆ្លើយតបហួសហេតុ ដូចអ្វីដែលគេបានមើលឃើញនៅក្នុងវប្បធម៌នៃអ្នកកាន់សាសនាគ្រឹស្ត ឬសាសនាឥស្លាមឡើយ។

នៅពេលដែលដំណាក់កាលនៃអរិយមគ្គអង្គ៨ដើម្បីឆ្ពោះទៅរកការត្រាស់ដឹងបានរៀបរាប់អំពីអំពីសកម្មភាពរួមភេទ គេមិនមានការហាមប្រាមជាក់លាក់ណាមួយនៃការរួមភេទដូចគ្នាឡើយ។ ដំណាក់កាលទី២បាននិយាយថា “អ្នកត្រូវតែលះបង់នូវភាពសប្បាយរីករាយទាំងអស់។”[16] នេះសំដៅទៅលើគ្រប់

---

[14] ដូចខាងលើ។

[15] អាឡិច ស្ពីលើស “ខ្ញុំមិនមែនប្រុសស្រលាញ់ប្រុសទេ មហាក្សត្រដែលមានអាយុ៨១ឆ្នាំ និងមានកូន១៤នាក់“ សារព័ត៌មានដេលីតេលេក្រាហ្វ ចុះផ្សាយថ្ងៃទី២៥ កុម្ភៈ ២០០៤។ អាចរកបាននៅ http://www.telegraph.co.uk/news/worldnews/asia/cambodia/1455293/Im-not-gay-says-81-year-old-monarch-with-14-children.html

[16] អរិយមគ្គអង្គ៨នៃពុទ្ធសាសនា *ពុទ្ធសាសនា និងការរួមភេទ។* អត្ថបទលើប្រព័ន្ធអ៊ីនធើណេតដែលមិនមានកាលបរិច្ឆេទ។ អាចរកបាននៅ http://www.religioustolerance.org/hom_budd0.htm ។

រូបភាពនៃសកម្មភាពផ្លូវភេទ ប៉ុន្តែបានទាមទារភាពឲ្យនៅលីវទាំងស្រុងទេ។ ដំណាក់កាលទី៥បានហាមឃាត់ "សកម្មភាពផ្លូវភេទខុសច្បាប់"។[17] អ្នកសិក្សារៀនសូត្រពីពុទ្ធសាសនាតែងតែបកប្រែទង្វើបែបនេះថាជា "ការរំលោភ ការបៀតបៀនផ្លូវភេទ ការបំពានផ្លូវភេទលើកុមារ និងការមិនស្មោះត្រង់ជាមួយដៃគូ"។[18] គេមិនមានការដាក់កម្រិតរវាងអាកប្បកិរិយានៃការរួមភេទដូចគ្នា ឬខុសគ្នាឡើយ គឺថាវាត្រូវតែគ្មានការឈឺចាប់ ហើយត្រូវបានធ្វើឡើងក្នុងគោលបំណងបង្ហាញពីការស្រលាញ់ដោយគោរព និងផ្ដល់ភាពសប្បាយរីករាយឲ្យគ្នាទៅវិញទៅមក។[19]

ដោយខុសប្លែកពីការយល់ឃើញនៃបរិបទវប្បធម៌ និងការយល់ឃើញក្នុងសង្គម ពុទ្ធសាសនាមិនបានផ្ដល់តម្លៃលើអាពាហ៍ពិពាហ៍ ឬការបង្កើតកូនឡើយ។ អាពាហ៍ពិពាហ៍ និងការបង្កើតកូនអាចត្រូវបានគេមើលឃើញថាជាភាពវិជ្ជមាន ប្រសិនបើបាននាំមកនូវក្ដីស្រលាញ់ និងការគោរព។ ប៉ុន្តែអាច មានផលអវិជ្ជមាន ប្រសិនបើមានការឈឺចាប់ ឬបញ្ហា។ ភាពនៅលីវតែងតែទទួលបានការគោរពនៅក្នុងពុទ្ធសាសនា ដើម្បីជាការសង្ឃឹមក្នុងការសម្រេចបានការត្រាស់ដឹងកម្រិតខ្ពស់។ គេមិនបានភ្ជាប់ការពេបជ្រាយទៅនឹងមនុស្សដែលគ្មានកូន ឬមិនបានរៀបការឡើយ។ នៅកម្ពុជា សំពាធផ្នែកវប្បធម៌ សង្គម និងសេដ្ឋកិច្ចបានបដិសេធចោលនូវទ្រឹស្ដីនាំពុទ្ធសាសនាលើអាពាហ៍ពិពាហ៍។ តម្លៃគ្រួសារមានសារៈសំខាន់យ៉ាងខ្លាំង និងបានដាក់សំពាធយ៉ាងធ្ងន់ទៅលើកូនប្រុស និងកូនស្រីក្នុងការរៀបការ និងមានកូន។

## ការទទួលស្គាល់ផ្នែកនយោបាយ

នៅឆ្នាំ២០០៤ អតីតព្រះមហាក្សត្រ នរោត្តម សីហនុ បានឆ្លើយតបនៅលើគេហទំព័ររបស់ទ្រង់ទៅនឹងសេចក្ដីរាយការណ៍តាមសារព័ត៌មានស្ដីពីអាពាហ៍ពិពាហ៍នៃអ្នកស្រលាញ់ភេទដូចគ្នានៅទីក្រុងសាន់ហ្វ្រាន់ស៊ីស្កូ ដោយបានរៀបរាប់ថាជា "លទ្ធិប្រជាធិបតេយ្យសេរី" ហើយកម្ពុជាគួរតែអនុញ្ញាតឲ្យមាន "អាពាហ៍ពិពាហ៍រវាងបុរស និងបុរស ឬរវាងស្ត្រី និងស្ត្រី"[20]។ សម្ដេចបានសម្ដែងនូវការគោរពរបស់ទ្រង់ចំពោះបុរសស្រលាញ់បុរស និងស្ត្រីស្រលាញ់ស្ត្រី ដោយមានព្រះរាជបន្ទូលថា "ពួកគេគឺជាពួកគេ" ដោយសារ ព្រះស្រលាញ់រសជាតិគ្រប់បែបយ៉ាងនៃជីវិត ។"[21] ហើយព្រះអង្គក៏បានលើកឡើងទៀតថា ភេទទីបីគួរតែត្រូវបាន "ទទួលស្គាល់ និងយកចិត្តទុកដាក់នៅក្នុងសហគមន៍ជាតិ។"[22] អតីតរដ្ឋមន្ត្រី

---

[17] ដូចខាងលើ។

[18] យេរី ត្រាំបាត់ *ពុទ្ធសាសនា និងការរួមភេទ*។ អត្ថបទលើប្រព័ន្ធអ៊ីនធើណេតដែលមិនមានកាលបរិច្ឆេទ។ អាចរកបាននៅ http://www.enabling.org/ia/vipassana/Archive/T/Trembath/buddhismAndHomosexualityTrembath.html។

[19] ដូចខាងលើ។

[20] "ព្រះមហាក្សត្រកម្ពុជាគាំទ្រអាពាហ៍ពិពាហ៍ភេទដូចគ្នា" សារព័ត៌មានប៊ីប៊ីស៊ី ចេញផ្សាយថ្ងៃទី ២០ កុម្ភៈ ២០០៤។ អាចរកបាននៅ http://news.bbc.co.uk/2/hi/asia-pacific/3505915.stm។

[21] ដូចខាងលើ។

[22] ដូចខាងលើ។

ក្រសួងកិច្ចការនារី លោកជំទាវ មូរ សុខហួរ បានបង្ហាញនូវការគាំទ្រទៅដល់ពលរដ្ឋខ្មែរដែលជាអ្នកភេទទីបីផងដែរ។[23]

ក៏ប៉ុន្តែ ជាទូទៅអ្នកនយោបាយហាក់ដូចជាមិនចាប់អារម្មណ៍នឹងកង្វល់របស់អ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជាសោះ។ វាហាក់ដូចជាថា សិទ្ធិអាពាហ៍ពិពាហ៍នៃភេទដូចគ្នានឹងមិនទំនងជារបៀបវារៈរបស់រដ្ឋាភិបាលក្នុងរយៈពេលឆាប់ៗនេះទេ។ ដូចដែលសារព័ត៌មាន ឌឹ ភ្នំពេញប៉ុស្ដិ៍បានរាយការណ៍ថា ឯកឧត្តម ជាម យៀប តំណាងរាស្ត្រមកពីគណបក្សប្រជាជន បានពន្យល់ថាហេតុអ្វីបានជាសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នាមិនមែនជាអាទិភាពរបស់រដ្ឋាភិបាល ដោយបាននិយាយថា “មកទល់ពេលនេះ យើងមានត្រឹមតែទំនៀមទម្លាប់ដែលបុរសរៀបការជាមួយនារី។ រដ្ឋាភិបាលត្រូវតែផ្ដោតលើការអភិវឌ្ឍប្រទេស មុនពេលបានចាប់ផ្ដើមគិតអំពីច្បាប់អាពាហ៍ពិពាហ៍នៃអ្នកស្រលាញ់ភេទដូចគ្នា។”[24]

នៅក្នុងអត្ថបទដដែលនោះផងដែរ ឯកឧត្តម សុន ឆ័យ អ្នកតំណាងរាស្ត្រគណបក្សសមរង្ស៊ីបាននិយាយថា ប្រទេសកម្ពុជាមិនមានប្រពៃណី ឬទំនៀមទម្លាប់ក្នុងការទទួលស្គាល់អ្នកដែលស្រលាញ់ភេទដូចគ្នាដូចនៅប្រទេសអឺរ៉ុបទេ។ តាមដែលលោកបានដឹង គេនៅមិនទាន់មានសំណើរសុំជាផ្លូវការណាមួយត្រូវបានរៀបចំឡើងទៅកាន់រដ្ឋាភិបាលក្នុងការធ្វើឲ្យអាពាហ៍ពិពាហ៍ភេទដូចគ្នាស្របច្បាប់នៅឡើយទេ។ ឯកឧត្តមបាននិយាយទៀត ថាយើងប្រហែលពិចារណាអំពីការធ្វើច្បាប់អាពាហ៍ពិពាហ៍នៃអ្នកស្រលាញ់ភេទដូចគ្នា ប្រសិនបើយើងទទួលបានការស្នើសុំពីអ្នកស្រលាញ់ភេទដូចគ្នាទាំងនោះ។”[25]

ក៏ប៉ុន្តែ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ហាក់ដូចជាបានផ្តល់នូវសារមិនច្បាស់លាស់លើគាំទ្រទៅដល់អ្នកស្រលាញ់ភេទដូចគ្នាកម្ពុជា។ នៅឆ្នាំ២០០៧ សម្តេចបានកាត់កាល់កូនស្រីចិញ្ចឹមជាសាធារណៈនៅក្នុងសន្ទរកថាទៅកាន់និស្សិតបញ្ចប់ការសិក្សា ដោយលើកឡើងពីការដែលថា នាងជាមនុស្សស្រីស្រលាញ់ស្រីដូចគ្នា។ សម្តេចបាននិយាយថា "ខ្ញុំមានបញ្ហារបស់ខ្ញុំ។ កូនស្រីចិញ្ចឹមរបស់ខ្ញុំមានប្រពន្ធ។ ឥឡូវនេះ ខ្ញុំនឹងសុំឲ្យតុលាការកាត់កាល់នាងពីគ្រួសាររបស់ខ្ញុំ។"[26] ទោះបីជាយ៉ាងនេះក្ដី

---

[23]ក្រុមប្រឹក្សាអន្តោប្រវេសន៍ និងជនភៀសខ្លួនកាណាដា ព័ត៌មានប្រុសស្រលាញ់ស្រុសនៅអាស៊ីដោយ *Utopia* ៖ គណបក្សរាជានិយមកម្ពុជាចែចង់អ្នកបោះឆ្នោតភេទទីបី ចេញផ្សាយថ្ងៃទី ២០ កក្កដា ២០០៣។ អាចរកបានៅ http://www.utopia-asia.com/unews/article_2003_07_20_210927.htm។ អ្នកស្រី មូរ សុខហួរបានទៅជួបសហគមន៍អ្នកភេទទីបីដែលងាយរងគ្រោះ ដោយទទួលស្គាល់អំពីការខ្វះខាតការតំណាងនៅក្នុងសង្គម និងនិយោបាយនៅកម្ពុជា និងធ្វើការប្តេជ្ញាថានឹងតស៊ូដើម្បីទទួលបានការគោរព និងសមភាពច្រើនជាងនេះ។

[24] គាំ ទិវា និងម៉េង ហឿង “ដូចៗគ្នា ប៉ុន្តែរៀបការបាន” សារព័ត៌មាន ឌឹ ភ្នំពេញបុស្ត៍ ចេញផ្សាយថ្ងៃទី ២២ កញ្ញា ២០១០។

[25] គាំ ទិវា និងម៉េង ហឿង “ដូចៗគ្នា ប៉ុន្តែរៀបការបាន” សារព័ត៌មាន ឌឹ ភ្នំពេញបុស្ត៍: ឡៃហ៍ ចេញផ្សាយថ្ងៃទី ២២ កញ្ញា ២០១០ អាចរកបាននៅ http://www.phnompenhpost.com/index.php/2010092242205/LIFT/same-same-but-married.html។

[26] រ៉យទ័រ *សម្តេច ហ៊ុន សែនរងការរិះគន់ដោយសារកាត់កាលកូនស្រី* ចេញផ្សាយថ្ងៃទី ៣១ តុលា ២០០៧។ អាចរកបាននៅ http://www.reuters.com/article/idUSBKK11415620071031។

នៅក្នុងសន្ទរកថាដដែលនោះ សម្តេចបានជម្រុញឲ្យប្រជាជនកម្ពុជាកុំយកគំរូតាមសម្តេច។ "ខ្ញុំជម្រុញឲ្យឪពុកម្តាយដែលមានកូនស្រលាញ់ភេទដូចគ្នាកុំរើសអើងនឹងពួកគេ និងកុំប្រមាទពួកគេ ដោយសារពួកគេជាមនុស្សភេទទីបីឲ្យសោះ។”[27]

[27] ដូចខាងលើ។

# ៣. ស្ថានភាពបច្ចុប្បន្ននៃអ្នកស្រលាញ់ភេទដូចគ្នា នៅកម្ពុជា

ការរួមភេទដូចគ្នាគឺមិនខុសច្បាប់នៅកម្ពុជា និងគ្មានទំនៀមទម្លាប់សាសនាប្រឆាំងនឹងអ្នកស្រលាញ់ភេទដូចគ្នាឡើយ។ កត្តាទាំងអស់នេះអាចបង្ការទប់ស្កាត់ភាពធ្ងន់ធ្ងរនៃការធ្វើទុក្ខបុកម្នេញលើអ្នកស្រលាញ់ភេទដូចគ្នាដូចនៅប្រទេសអាហ្វ្រិក និងប្រទេសឥស្លាមជាដើម។ ក៏ប៉ុន្តែ អ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជានៅតែប្រឈមនឹងការរើសអើង និងការរំលោភបំពានពីសមាជិកគ្រួសារ សង្គម និយោជក អាជ្ញាធរ អ្នកនយោបាយ និងប៉ូលីស។

## កង្វះខាតការយល់ដឹងនៅក្នុងក្រុមគ្រួសារ និងសហគមន៍

សង្គមកម្ពុជាអាចមានការសណ្តោសប្រណីចំពោះសកម្មភាពរួមភេទរវាងបុរសដូចគ្នា (ក្នុងករណី"សក់ខ្លី" និង"បុរសពិត") ប្រសិនណាបើគ្មានការជាប់ទាក់ទងនិងមិនបានប៉ះពាល់ដល់រចនាសម្ព័ន្ធគ្រួសារជាប្រពៃណី។ អាកប្បកិរិយានៃការរួមភេទក្នុងចំណោម យុវជនអាចត្រូវបានគេមើលឃើញថាជាការសាកល្បងដោយគ្មានគ្រោះថ្នាក់ ដោយសារគេបានគិតថាស្ត្រីនៅតែមានភាពបរិសុទ្ធរហូតដល់ពេលរៀបការ។ គេអាចបំភ្លេចចោល ឬបន្តមិនយកចិត្តទុក ដាក់លើការធ្វេសប្រហែសរបស់យុវជន។ ក៏ប៉ុន្តែ នៅទីបញ្ចប់ បុរសនឹងអាចរៀបការ និងក្លាយជាឪពុកកុមារ។

ស្ថានការណ៍នេះបានធ្វើឲ្យមានការភាន់ច្រឡំនៅក្នុងចំណោមយុវជន។ បុគ្គលដែលជាបុរសស្រលាញ់បុរសម្នាក់មកពីទីរួមខេត្តបាត់ដំបងនិយាយថា " *អ្នករាល់គ្នានិយាយថា អ្នកដែលបុរសស្រលាញ់បុរសមិនមែនជាវប្បធម៌របស់យើងទេ។ តើខ្ញុំអាចធ្វើជាបុរសស្រលាញ់បុរសបានយ៉ាងដូចម្តេចទៅ?"*[28] កាលពីឆ្នាំមុន ឪពុកម្តាយរបស់គាត់បានសុំគាត់ឲ្យរៀបការជាមួយស្ត្រីម្នាក់។ គាត់បានធ្វើទៅតាមការស្នើសុំនោះ។ ប៉ុន្តែ នៅពេលឪពុកម្តាយនាំគាត់ទៅជួយគ្រួសារខាងស្រី ក្មេងស្រីម្នាក់នោះបានសង្ស័យពីសមត្ថភាពធ្វើជាប្តីរបស់នាង (នៅក្នុងសំដីរបស់នាងថា *"មិនដូចប្រុសមិនដូចស្ត្រី។"* )[29] ។ នេះបានធ្វើឲ្យគាត់មិនអាចទទួលបាននូវទំនាក់ទំនងជាមួយបុរសម្នាក់ ឬស្ត្រីម្នាក់ មានន័យថា " *បើខ្ញុំចង់រស់នៅ*

[28] ដូចខាងលើ។
[29] ដូចខាងលើ។

*ជាមួយក្មេងប្រុស អ្នករាល់គ្នានឹងសើចខ្ញុំ។ ប៉ុន្តែបើខ្ញុំធ្វើតាមឪពុកម្តាយរបស់ខ្ញុំ ហើយរៀបការជាមួយក្មេងស្រីខ្ញុំក៏នឹងសើចចំអកឲ្យខ្ញុំដែរ។*[30]

ដោយសារតួនាទីផ្នែកយេនឌ័រពីប្រពៃណី ស្ត្រីមានលទ្ធភាពតិចតួចក្នុងការបង្កើតទំនាក់ទំនងភេទដូចគ្នាជាងបុរសស្រលាញ់បុរស ទាំងនៅកំរិតផ្ទាល់ខ្លួន ឬបើកជំហជាសាធារណៈ។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបាននិយាយទៅកាន់ស្ត្រីស្រលាញ់ស្ត្រីដូចគ្នាមួយក្រុមនៅសៀមរាប។ ក្រុមមួយមានគ្នាបីនាក់ស្លៀកពាក់ដូចប្រុស ហើយអ្នកផ្សេងទៀតស្លៀកពាក់ដូចស្រី។ បន្ទាប់ពីការពិភាក្សាយ៉ាងយូរ វាច្បាស់លាស់ថាអ្នកដែលបានតុបតែងជាស្រីគឺដើម្បីភាពងាយស្រួលនៅក្នុងសង្គម។ ក្មេងស្រីម្នាក់បានពន្យល់ថា " *ខ្ញុំត្រូវការលាក់ខ្លួនពីឪពុកម្តាយខ្ញុំ ពីព្រោះពួកគាត់ស្អប់អ្នកដែល ជាស្ត្រីស្រលាញ់ស្ត្រី។*" [31] បញ្ហាសំខាន់ពីរដែលបង្ហាញដោយស្ត្រីទាំងនេះគឺស្វែងរកការងារធ្វើហើយ អាចស្រលាញ់ម្នាក់ និងអាចបង្កើតគ្រួសារមួយ។

ទំនាក់ទំនងរវាងស្ត្រីស្រលាញ់ស្ត្រីដូចគ្នាគឺពិបាកយល់ណាស់នៅក្នុងសង្គមកម្ពុជា ដែលអាចនាំឲ្យមានស្ថានភាពដែលសមាជិកគ្រួសារបានប្រើប្រាស់គ្រប់មធ្យោបាយដើម្បីបំបែកបំបាក់ទំនាក់ទំនងរវាងភេទដូចគ្នា។ ជាឧទាហរណ៍ ករណីមួយទៀតដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បានដឹងគឺស្ត្រីស្រលាញ់ស្ត្រីដូចគ្នាម្នាក់ដែលមានអាយុជាង២០ឆ្នាំរស់នៅទីក្រុងភ្នំពេញ។ ឪពុកម្តាយរបស់នាងបានចាត់ចែងឲ្យនាងរៀបការ តែនាងបានរត់គេចនៅមុនពិធីរៀបការ។ បន្ទាប់មក នាងត្រលប់មកវិញ។ ឪពុកម្តាយបានដឹងថានាងជាមនុស្ស ស្ត្រីស្រលាញ់ស្ត្រីដូចគ្នា និងដឹងថានាងមានទំនាក់ទំនងជាមួយស្ត្រីម្នាក់ទៀតអស់រយៈពេលជាច្រើនឆ្នាំ។ នៅពេលដែលនាងរត់ម្តងទៀត ឪពុកម្តាយបានប្តឹងប៉ូលីសដែលបានឃុំឃាំងគូស្នេហ៍របស់នាង នៅពេលដែលស្ត្រីម្នាក់ទៀតនោះមិនព្រមប្រាប់ថានាងនៅទីណា។ នៅពេលដែលនាងត្រូវបានប៉ូលីសរកឃើញ នាងត្រូវបានបង្ខំឲ្យត្រលប់មកផ្ទះវិញ។ ដើម្បីកុំឲ្យនាងរត់ចេញពីផ្ទះម្តងទៀត សមាជិកគ្រួសារម្នាក់បានចងដៃរបស់នាងជាប់នឹងកៅអីអស់រយៈពេល២ថ្ងៃ។ ឥឡូវនេះគូស្នេហ៍ស្ត្រីស្រលាញ់ស្ត្រីដូចគ្នានេះរស់នៅបែកពីគ្នា ប៉ុន្តែនៅតែទាក់ទងគ្នាតាមទូរស័ព្ទ។[32]

ស្ត្រីស្រលាញ់ស្ត្រីដូចគ្នាម្នាក់មកពីខេត្តបាត់ដំបងបាននិយាយមកកាន់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាថា "*តើហេតុដូចម្តេចបានជាឪពុកម្តាយរបស់ខ្ញុំបង្ខំខ្ញុំឲ្យរៀបការ ដោយមិនមានការដាក់ទោសពីសង្គមឬអាជ្ញាធរ? ខ្ញុំចង់រស់នៅជាមួយអ្នកដែលខ្ញុំស្រលាញ់។ ពួកគេបញ្ឈប់ខ្ញុំមិនឲ្យនិយាយជាមួយមនុស្សស្រី ហើយគ្រួសារមិត្តស្រីរបស់ខ្ញុំឈប់ឲ្យនាងមកជួបខ្ញុំ។ តើខ្ញុំអាចដោះស្រាយដោយរបៀបណា និងអ្នកណាអាចជួយយើងបាន?*"[33]

---

[30] ដូចខាងលើ។

[31] បទសម្ភាសន៍ធ្វើឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានៅខេត្តសៀមរាប កាលពីថ្ងៃទី ១៩ កញ្ញា ២០១០។

[32] បទសម្ភាសន៍ធ្វើឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានៅខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ២ កញ្ញា ២០១០។

[33] បទសម្ភាសន៍ធ្វើឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានៅខេត្តបាត់ដំបង កាលពីថ្ងៃទី ៣០ កញ្ញា ២០១០។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានដឹងថាមានស្ត្រីស្រលាញ់ស្ត្រីដូចគ្នាដែលត្រូវបានឪពុកម្តាយបញ្ជូនឲ្យទៅរៀននៅបរទេស ដើម្បីបំបែកពួកគេមឲ្យជួបដៃគូស្ត្រីស្រលាញ់ស្ត្រីដូចគ្នា និងកុំឲ្យមានភាពខ្មាស់អៀនដល់ក្រុមគ្រួសារគេ។

នៅខេត្តបាត់ដំបង ស្ត្រីម្នាក់បានពន្យល់ថាដើម្បីបំពេញចិត្តឪពុកម្តាយរបស់នាង នាងបាន យល់ព្រមរៀបការជាមួយបុរសម្នាក់។ ប៉ុន្តែប្តីរបស់នាងដឹងថានាងស្រលាញ់ស្ត្រីម្នាក់ គាត់បដិសេដមិនទទួលយកអាកប្បកិរិយារបស់នាង។ ហើយនៅពេលដែលនាងនិយាយទៅកាន់ស្ត្រីដទៃទៀត គាត់នឹងខឹងហើយជួនកាលគាត់ប្រើអំពើហិង្សាមកលើនាង។ នាងចង់ដាក់ពាក្យបណ្តឹងទៅតុលាការ តែនាងខ្លាចតុលាការ និងប៉ូលីសមិនទទួលយកពាក្យបណ្តឹងរបស់នាង។[34]

កាលថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១០ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា រួមគ្នាជាមួយសហគមន៍ឥន្ទធនូកម្ពុជា (“RoCK”)[35] បានរៀបចំសិក្ខាសាលាពីសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នាមួយនៅភ្នំពេញដើម្បីឲ្យអ្នកស្រលាញ់ភេទដូចគ្នាបានជួបគ្នាពិភាក្សាពីបញ្ហាដែលប៉ះពាល់ពួកគេ និងសិទ្ធិរបស់ពួកគេ។[36] សិក្ខាសាលានេះក៏បានផ្តល់វេទិកាមួយសម្រាប់អ្នកចូលរួមបានពិភាក្សាពីការរើសអើង និងការរំលោភបំពានដែលពួកគេបានជួបប្រទះ។ គេបានសង្កេតឃើញមានភាពទូទៅដែលអ្នកចូលរួមបាននិយាយថា ពួកគេបានរក្សាទុកអត្តសញ្ញាណអ្នកស្រលាញ់ភេទដូចគ្នាជាការសម្ងាត់។ ក៏ប៉ុន្តែ អ្នកដែលមិនអាចរក្សាភាពសម្ងាត់បាន ឬមិនចង់លាក់ពីអត្តសញ្ញាណបែបនេះតែងតែទទួលរងការមិនរាប់រកពីសំណាក់ក្រុមគ្រួសារ និងសហគមន៍របស់ពួកគេ។ ការណ៍នេះបានបណ្តាលឲ្យអ្នកស្រលាញ់ភេទដូចគ្នាជួបការលំបាកផ្នែកសេដ្ឋកិច្ច ហើយបានធ្វើឲ្យខ្លួនឯងកាន់តែងាយរងគ្រោះថ្នាក់ជាងមុន ដោយសារមិនមានការគាំទ្រពីមិត្តភក្តិ និងគ្រួសារ។

## សំពាធផ្នែកសេដ្ឋកិច្ច និងការរើសអើងលើការងារ

ដោយហេតុថាគេបានផ្តោតទៅលើអាពាហ៍ពិពាហ៍ និងការមានកូន អ្នកស្រលាញ់ភេទដូចគ្នាភាគច្រើននឹងទទួលរងសម្ពាធពីគ្រួសារដើម្បីបន្តវេនក្នុងគ្រួសារ។ ក្រៅពីនេះ កង្វះខាតនៃប្រព័ន្ធសុវត្ថិភាពសង្គមបានបង្ហាញថាអ្នកជំនាន់មុនបានទទួលបន្ទុកយ៉ាងធ្ងន់ធ្ងរក្នុងការគាំទ្រ និងថែទាំអ្នកជំនាន់ក្រោយនៃគ្រួសារ។ ដោយសារហេតុផលទាំងនេះ ប្រតិកម្មរបស់អាណាព្យាបាលទៅលើកូនដែលជាអ្នកស្រលាញ់

[34] ដូចខាងលើ។

[35] RoCK ក្រុមការងារដែលទទួលខុសត្រូវរៀបចំកម្មវិធីមោទនភាព គឺជាក្រុមស្ម័គ្រចិត្តមិនរកប្រាក់កំរៃមួយដែលមានគោលបំណងគាំទ្រអ្នកស្រលាញ់ភេទដូចគ្នាកម្ពុជា តាមរយៈការទទួលស្គាល់ និងលើកកម្ពស់ការទាមទារនូវសមភាព និងការគោរពដោយមិនគិតអំពីទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ។

[36] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និង RoCK សិក្ខាសាលាធ្វើឡើងនៅថ្ងៃទី ១៥ ឧសភា ២០១០ នៅភ្នំពេញ។

ភេទគឺខ្លាំងណាស់ ដែលឈានទៅដល់ការចាត់វិធានការណ៍ហួសហេតុដើម្បីរារាំងកូនមិនឲ្យបង្កើតទំនាក់ទំនងបែបនេះ ដែលអាចត្រូវបានគេមើលឃើញថាជាភាពអាម៉ាស់សម្រាប់គ្រួសារ។

ការស្វែងរកទំនាក់ទំនងរវាងភេទដូចគ្នាគឺជាវិធីមួយដែលបុគ្គលភាគច្រើនមិនមានលទ្ធភាព ផ្នែកសង្គម និងផ្នែកសេដ្ឋកិច្ចក្នុងការស្វែងរកបាន។ ភាពគ្រោះថ្នាក់នៃការផាត់ចេញពីសមាជិកគ្រួសារដែលជិតស្និត និងការលំបាកផ្នែកសេដ្ឋកិច្ច ដោយសារការរស់នៅក្រៅពីសមាជិកគ្រួសារអាចបញ្ជាក់ថាអ្នកស្រលាញ់ភេទដូចគ្នាមិនអាចរស់នៅបានតាមដែលពួកគេចង់បាន ឬចាំបាច់ត្រូវតែមានទំនាក់ទំនងផ្លូវភេទដូចគ្នាដោយសម្ងាត់។ ហេតុដូចនេះ ការរស់រានផ្នែកសេដ្ឋកិច្ច និងភាពជាក់ស្តែងនឹងកើតមានឡើងជុំវិញការបង្ហាញពីអត្តសញ្ញាណផ្ទាល់ខ្លួន និងផ្លូវភេទ។

ការសំពាធសេដ្ឋកិច្ចបណ្តាលមកពីការខ្វះខាត ការគាំទ្រផ្នែកប្រពៃណីគ្រួសារអាចមានន័យថា អ្នកទាំងនោះជ្រើសរើសការរស់នៅតាមរបៀបរស់នៅរបស់អ្នកស្រលាញ់ភេទដូចគ្នា ដោយបើកចំហរជាមួយនឹងការប្រឈមមុខនូវអនាគតមិនពិតប្រាកដ។ *ស្រីស្រស់* ជាអ្នកដែលងាយរងគ្រោះជាពិសេស។ អ្នករកស៊ីផ្លូវភេទដែលជាអ្នកប្តូរភេទបានកត់សំគាល់ថា ការរើសអើងនៅក្នុងសហគមន៍ដែលទាក់ទងនិងអត្តសញ្ញាណយេនឌ័ររបស់ពួកគេបានធ្វើឲ្យពួកគេក្លាយជាពេស្យាចារ។ ជាឧទាហរណ៍

> " *ខ្ញុំបានចាកចេញពីផ្ទះ ដោយសារតែការរើសអើងពីឪពុកម្តាយរបស់ខ្ញុំ ពីព្រោះតែការប្តូរភេទរបស់ខ្ញុំ។ ខ្ញុំបានក្លាយជាអ្នករកស៊ីផ្លូវភេទ ចាប់តាំងពីខ្ញុំចាកចេញពីផ្ទះ ហើយខ្ញុំបានតាមមិត្តភក្តិរបស់ខ្ញុំក្នុងការរកលុយចិញ្ចឹមជីវិត តាមរយៈការរកស៊ីផ្លូវភេទ។*[37]

អ្នកចូលរួមនៅក្នុងសិក្ខាសាលក៏បានរៀបរាប់ពីការមិនរាប់រកពីសំណាក់គ្រួសារ ដែលធ្វើឲ្យមានការលំបាកផ្នែកសេដ្ឋកិច្ចដល់អ្នកស្រលាញ់ភេទដូចគ្នា ដែលកាន់តែមានភាពងាយរងគ្រោះខ្លាំងជាងមុននៅពេលគ្មានបណ្តាញគាំទ្រពីគ្រួសារ និងមិត្តភក្តិ។ អ្នកចូលរួមក៏បានកត់សម្គាល់ផងដែរថាពួកគេបានជួបប្រទះការរើសអើងនៅកន្លែងធ្វើការ និងនៅពេលដាក់ពាក្យធ្វើការ ដោយសារទំនោរផ្លូវភេទ និងរូបរាងរបស់ពួកគេ។ ជាពិសេស ស្ត្រីស្រលាញ់ស្ត្រីមួយចំនួន (ដែលបានរស់នៅតាមខេត្ត) បានជួបប្រទះការរំលោភបំពាន និងការរើសអើង ដោយសាររូបរាងកាយរបស់ពួកគេ។[38] ក្មេងស្រីនៅខេត្តសៀមរាបម្នាក់បានពន្យល់មកកាន់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាថា មិត្តភក្តិស្រីស្រលាញ់ស្រីរបស់នាងស្លៀកពាក់ដូចបុរស *"ខ្ញុំស្លៀកពាក់ដូចស្រី ដោយសារខ្ញុំត្រូវស្វែងរកការងារធ្វើ"* ។[39]

---

[37] ដូចខាងលើ។

[38] ដូចខាងលើ។

[39] បទសម្ភាសន៍ធ្វើឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានៅខេត្តសៀមរាប កាលពីថ្ងៃទី ១៩ កញ្ញា ២០១០។

## ការរើសអើង និងការរំលោភបំពានពីរដ្ឋ

នៅពេលដែលមនុស្សស្រលាញ់ភេទដូចគ្នាជាទូទៅណាស់ជួបប្រទះការរំលោភបំពានពីគ្រួសារ និងសហគមន៍ ពួកគេនៅពេលខ្លះបានទទួលរងការឈឺចាប់ពីសង្គមជាតិ តាមរយៈសកម្មភាពមួយចំនួនរបស់អាជ្ញាធរ។ ឧទាហរណ៍ មានរបាយការណ៍ (ដែលថ្មីៗបំផុតគឺនៅខេត្តកំពង់ឆ្នាំងដែលមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានលឺ) ថាបុរសដែលរួមភេទដូចគ្នាគឺជាគោលដៅនៃការកេងប្រវ័ញ្ចរបស់ប៉ូលីសដើម្បីទទួលបានលុយកាក់។ អ្នកដែលជាមុខសញ្ញាទាំងនោះបាននិយាយថា នៅកន្លែងសាធារណៈ ពួកគេត្រូវបានប៉ូលីសចាប់ខ្លួន ដោយសារបទចោទប្រកាន់មិនពិតប្រាកដ (ដែលតែងតែទាក់ទងទៅនឹងការជួញដូរមនុស្ស ប្រើប្រាស់គ្រឿងញៀន និងពេស្យាចារ) និងការប្រព្រឹត្តមិនត្រឹមត្រូវ។ ពួកគេបាននិយាយថា បើសិនជាពួកយើងមិនព្រមបង់លុយពី១០ទៅ៣០ដុល្លារទេ ប៉ូលីសនឹងឃុំឃាំងពួកគេមួយយប់។ បុរសទាំងនេះមានអារម្មណ៍ថាពួកគេមិនអាចធ្វើអ្វីបាន ដោយសារការពេបជ្រាយទាក់ទងនឹងការស្រលាញភេទដូចគ្នា។[40]

បុរសភេទទីបីម្នាក់នៅខេត្តបាត់ដំបងបានសម្តែងកង្វល់របស់ខ្លួនថា សកម្មភាពរបស់បុរសស្រលាញ់បុរសម្នាក់ ឬពីរបីនាក់អាចធ្វើឲ្យខូចមុខមាត់ដល់បុរសស្រលាញ់បុរសដូចគ្នាទាំងអស់នៅក្នុងចំណោមសាធារណៈជន តាមវិធីម្យ៉ាងដែលមិនបានកើតឡើងជាមួយការរួមភេទរវាងបុរស និងស្ត្រី។ គាត់បាននិយាយថា “ប្រសិនបើបុរសស្រលាញ់បុរសម្នាក់មានកំហុស សាធារណៈជននឹងគិតថាបុរសស្រលាញ់បុរសទាំងអស់គ្នាអាក្រក់ និងប្រឆាំងជាមួយធម្មជាតិ។”[41]

អ្នករកស៊ីផ្លូវភេទភេទទីបីបានរងការរើសអើង និងពេលខ្លះមានការរំលោភបំពានយ៉ាងឃោរឃៅពីសំណាក់ប៉ូលីស។ អ្នករកស៊ីផ្លូវភេទភេទទីបីបានរៀបរាប់ការរំលោភបំពានដូចខាងក្រោម:

> *ពេលខ្លះ “ប៉ូលីសនិយាថា អាខ្ទើយ (ពាក្យមួយសម្រាប់ហៅមនុស្សភេទទីបី) ហ្អែងចុយក្តិតរបស់ហ្អែងទៅ។ ហ្អែងកើតអេដស៍ ហើយហ្អែងបានចម្លងទៅមនុស្សផ្សេងទៀត។ ហ្អែងសមតែបាញ់ចោលទេ។”*[42]

> *“មន្ត្រីប៉ូលីសបីនាក់វាយខ្ញុំយ៉ាងធ្ងន់ធ្ងរនៅប៉ុស្តិ៍ប៉ូលីសសង្កាត់វត្តភ្នំ បន្ទាប់ពីគេបានចាប់ខ្ញុំនៅតាមសួនច្បារ។ មន្ត្រីប៉ូលីសម្នាក់បានភ្ជង់ក្បាលខ្ញុំនឹងកាំភ្លើង និងបានកេះកៃ តែគ្រាប់មិនផ្ទុះ។ ពួកគេធាក់ចំក ចង្កេះ និងវាយក្បាល និងខ្លួនប្រាណរបស់ខ្ញុំនឹងដងអំបោស អស់រយៈពេល*

[40] បទសម្ភាសន៍ធ្វើឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានៅខេត្តសៀមរាប កាលពីថ្ងៃទី ២៩ កញ្ញា ២០១០។
[41] បទសម្ភាសន៍ធ្វើឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានៅខេត្តបាត់ដំបង កាលពីថ្ងៃទី ៣០ កញ្ញា ២០១០។
[42] អង្គការឃ្លាំមើលសិទ្ធិមនុស្ស *នៅតាមដងផ្លូវ: ការឃុំឃាំងដោយគ្មានមូលហេតុច្បាស់ និងការរំលោភបំពានផ្សេងទៀតលើអ្នករកស៊ីផ្លូវភេទនៅកម្ពុជា*( វ៉ាស៊ីនតោន ឌីស៊ី អង្គការឃ្លាំមើលសិទ្ធិមនុស្ស ខែកក្កដា ២០១០) ទំព័រទី៣៣។

*ប្រហែលជាកន្លះម៉ោង។ ខ្ញុំអង្វរពួកគេកុំឲ្យវាយខ្ញុំ។ មន្ត្រីប៉ូលីសសាហាវណាស់ ហើយពួកគេមិនបានប្រាប់ខ្ញុំថាហេតុអ្វីពួកគេធ្វើដូចនេះទេ។”*[43]

*“ខ្ញុំគឺស្រីស្រស់ (ភេទទីបី)។ ខ្ញុំនៅលីវ និងរស់នៅជាមួយគ្រួសាររបស់ខ្ញុំ។ ខ្ញុំរកស៊ីផ្លូវភេទនេះអស់៣ទៅ៤ឆ្នាំហើយ ដោយសារគ្រួសារខ្ញុំបានរើសអើងនឹងខ្ញុំ។ សមាជិកគ្រួសាររបស់ខ្ញុំមិនចូលចិត្តខ្ញុំជាមនុស្សប្រុសពាក់កណ្ដាល ស្រីពាក់កណ្ដាលដូចនេះទេ។ ខ្ញុំរកស៊ីនៅតាមសួនច្បារ តាមផ្លូវ និងនៅវត្តសាល។ ខ្ញុំរងការរំលោភបំពានពីប៉ូលីសនៅតាមសួរច្បារ និងពីសំណាក់ភ្ញៀវបុរស ដូចជាការវាយដំ និងការរំលោភដោយមិនប្រើស្រោមអនាម័យ និងមិនឲ្យលុយ។”*[44]

អំពើហិង្សា ការពេបជ្រាយ និងការរើសអើងដែលអ្នកស្រលាញ់ភេទដូចគ្នាបានជួបប្រទះគឺអាចត្រូវបានពន្យល់ថាជាលទ្ធផលដោយសារការភាពភ័យខ្លាចនៃការស្រលាញ់ដូចគ្នា និងការស្រលាញ់ភេទផ្ទុយគ្នា (ការលំអៀង និងការរើសអើង ទៅរកការរួមភេទរវាងបុរស និងស្ត្រី។ អាកប្បកិរិយាដែលបានចាក់ឫសនៅក្នុងវប្បធម៌អភិរក្សនិយមនៅកម្ពុជាដែលបានផ្តល់តម្លៃទៅលើអាពាហ៍ពិពាហ៍ និងការរស់នៅក្នុងគ្រួសារតែមួយជាប្រពៃណី។[45] គ្រួសារអាចមានការភ័យខ្លាចថាកូនដែលមិនបានគោរពតាមប្រពៃណីនៃយែនឌ័រ និងទំនៀមទម្លាប់នៃការរួមភេទអាចនឹងនាំមកនូវរឿងអាស្រូវដល់គ្រួសារ និងជឿថាទំនាក់ទំនងអ្នកស្រលាញ់ភេទដូចគ្នាបានគំរាមកំហែងដល់រចនាសម្ព័ន្ធគ្រួសារជាប្រពៃណី ដែលមានដូចជាបណ្ដាញគាំទ្រផ្នែកសេដ្ឋកិច្ច។

អំពើហិង្សាលើអ្នកស្រលាញ់ភេទដូចគ្នាតែងតែបង្ហាញពីការពេបជ្រាយ និងការរើសអើងដែលកើតចេញមកពីការដែលបុគ្គលទាំងនោះមិនបានសម្របខ្លួនទៅក្នុងលក្ខណ:សម្បត្តិយែនឌ័រប្រពៃណី។[46] អ្នកដែលមានសិទ្ធិអំណាចនៅក្នុងប្រទេសដែលជម្រុញ និងត្រួតពិនិត្យការរើសអើង ឬអំពើហិង្សាលើអ្នកស្រលាញ់ភេទដូចគ្នាបានស្រមៃឃើញទាំងដឹងខ្លួន និងមិនដឹងខ្លួនថា សកម្មភាពនេះជាទណ្ឌកម្មទៅលើអ្នកដែលមិនបានគោរពតាមទំនៀមទម្លាប់ដែលគេបានទទួលយក។ ជនល្មើសអាចមានអារម្មណ៍ថាមានសិទ្ធិ ដោយមើលឃើញខ្លួនឯងថាមានឋាន:សង្គមខ្ពស់ជាង និងមានការគោរពផ្នែក

---

[43] ដូចខាងលើ ទំព័រទី៣៧។

[44] ខារ៉ូល ជែនគីន អំពើហិង្សា និងភាពគ្រោះថ្នាក់នៃជំងឺអេដស៍ក្នុងចំណោមអ្នករកស៊ីផ្លូវភេទនៅភ្នំពេញ កម្ពុជា (វ៉ាស៊ីនតោន ឌីស៊ី ២០០៦៖ DC: USAID ទំព័រទី១៥។ អាចរកបាននៅ http://www.hivpolicy.org/Library/HPP001702.pdf។

[45] មីរ៉ា បៃតុន និងអ៊ីវ៉ែន ហ្គុងសាលេស ហ្វីហ្គោរ្វ *ការកំនត់យែនឌ័រ និងអំពើសិង្សានៅក្នុងក្នុងបុរសស្រលាញ់បុរស និងអ្នកភេទទីបី៖ អនុសាសន៍គោលនយោបាយសំរាប់សេវាកម្មជំងឺអេដស៍* (វ៉ាស៊ីនតោន ឌីស៊ី ២០០៦៖ DC: USAID) ដែលអាចរកបាននៅ http://www.nfi.net/downloads/homepage/Other%20recent%20useful%20document-27%20july%202010/USAID-9129_Gender_Identity_and_Violence_in_MSM_and_Transgenders.pdf។

[46] ដូចខាងលើ។

សីលធម៌ខ្ពស់ជាងអ្នកស្រលាញ់ភេទដូចគ្នាដែលត្រូវបានគេចាត់ទុកថាមិនស្អាតបាតផ្នែកសីលធម៌ និងជាពលរដ្ឋលំដាប់ថ្នាក់ទីពីរ។[47]

អ្វីដែលបានរៀបរាប់ខាងលើគឺគ្រាន់តែជាឧទាហរណ៍មួយចំនួននៃការរើសអើង និងការរំលោភបំពានដែលអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជាកំពុងទទួលរង។ ប៉ុន្តែ ការទទួលបានព័ត៌មានទាំងនេះមិនមែនជាការងាយស្រួលឡើយ។ អ្នកស្រលាញ់ភេទដូចគ្នាតិចតួចដែលធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាចង់ផ្តោតជាសំខាន់ទៅលើការផ្តល់នូវសេវាសុខភាព និងជម្ងឺអេដស៍មិនបានចងក្រងឯកសារ និងរបាយការណ៍អំពីការរំលោភបំពាន និងការរើសអើងទេ។ ហេតុដូច្នេះហើយ ការផ្តល់អំណាចដល់ក្រុមអ្នកស្រលាញ់ភេទដូចគ្នាក្នុងការចងក្រងឯកសារ និងរាយការណ៍ពីករណីរំលោភបំពាន និងការរើសអើងនឹងក្លាយជាផ្នែកសំខាន់មួយនៃគម្រោងសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នានេះរយៈពេលបីឆ្នាំខាងមុខនេះ។

[47] ដូចខាងលើ។

# ៤. សិទ្ធិមនុស្ស និងសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា

មនុស្សស្រលាញ់ភេទដូចគ្នាមានសិទ្ធិគ្រប់យ៉ាងដូចមនុស្សឯទៀតដែរ។ ច្បាប់កម្ពុជា និងច្បាប់អន្តរជាតិបានហាមឃាត់ការរើសអើងលើបុគ្គលទាំងអស់ ដោយសារផ្អែកលើបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនរបស់ពួកគេ និងធានាបាននូវសិទ្ធិ និងសេរីភាពស្មើគ្នា និងការអនុវត្តច្បាប់ស្មើគ្នាលើបុគ្គលទាំងអស់។ ទំនោរផ្លូវភេទ និងការកំនត់យែនឌ័រអាចត្រូវបានចាត់ទុកថាជាមូលហេតុនៃការរើសអើងដែលត្រូវបានហាមឃាត់ ដោយយោងទៅលើបញ្ញត្តិច្បាប់ស្តីពីការរើសអើងលើ"ផ្លូវភេទ" និង"ពាក្យសម្ដីបណ្ដោះអាសន្ន" ឬ"ស្ថានភាពផ្សេងទៀត"។នេះមានន័យថាមនុស្សស្រលាញ់ភេទដូចគ្នាមានសិទ្ធិគ្រប់យ៉ាងដូចដែលបានចែងនៅក្នុងច្បាប់កម្ពុជា និងបានកំនត់នៅក្នុងលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិ ដូចជាសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិ មនុស្ស កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ បើទោះបីជាមានការហាមឃាត់លើការរើសអើង ច្បាប់សិទ្ធិមនុស្សអន្តរជាតិមកទល់សព្វថ្ងៃនេះបានទទួលការបរាជ័យក្នុងការទទួលស្គាល់ឲ្យបានច្បាស់ពីសិទ្ធិ ដោយយោងទៅលើទំនោរផ្លូវភេទ។ ផ្នែក ៤.៣ នឹងពិនិត្យមើលពីការវិវត្តន៍បច្ចុប្បន្ននៃបញ្ហានេះ។

## ច្បាប់ជាតិ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (រដ្ឋធម្មនុញ្ញ) គឺជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់ផ្សេងៗទៀតត្រូវតែស្របតាមគោលការណ៍នៃរដ្ឋធម្មនុញ្ញ និងកំនត់អំពីការធានាអះអាង។[48] មាត្រា៣១នៃរដ្ឋធម្មនុញ្ញដែលបានធានាអំពីសិទ្ធិស្មើគ្នាដោយមិនគិតអំពីចរិតលក្ខណៈផ្ទាល់ខ្លួនចែងថា

> "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា...និងស្ថានភាពឯទៀតឡើយ។"

មាត្រា៣៥បានធានាអំពីសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដោយមិនគិតអំពីភេទ ក្នុងការចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ។ បើទោះបីជាមិនមានការនិយាយឲ្យបានចំៗអំពីភេទនៅក្នុងបញ្ញត្តិទាំងនេះក៏ដោយ នេះមានន័យថាវិសាលភាពនៃច្បាប់បានគ្របដណ្ដប់ទៅដល់ទៅបុគ្គលដែលស្រលាញ់ភេទដូចគ្នា ក្នុងគោលបំណងដើម្បីធានាអំពីសមភាព ដោយមិនគិតអំពីចរិតលក្ខណៈផ្ទាល់ខ្លួន។

[48] មាត្រា ១៦–១៩នៃច្បាប់ស្ដីពីការរៀបចំ និងដំណើរការនៃក្រុមប្រឹក្សាធម្មនុញ្ញ ដោយឲ្យអំណាចដល់ក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិចារណាអំពីធម្មនុញ្ញភាពនៃច្បាប់។

ការស្រលាញ់ភេទដូចគ្នាមិនខុសច្បាប់ទេនៅកម្ពុជា ប៉ុន្តែអាពាហ៍ពិពាហ៍នៃភេទដូចគ្នាត្រូវបានហាមឃាត់។ មាត្រា៩៥នៃរដ្ឋធម្មនុញ្ញបានកំនត់យ៉ាងច្បាស់លាស់ថា អាពាហ៍ពិពាហ៍គឺជាការព្រមព្រៀងរវាងប្តី និងប្រពន្ធ ហើយទស្សនៈប្រពៃណីនៃអាពាហ៍ពិពាហ៍គឺត្រូវបញ្ជាក់ឡើងវិញនៅក្នុងមាត្រា៣នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារដែលបានចែងថា "អាពាហ៍ពិពាហ៍គឺជាកិច្ចសន្យាយ៉ាងឱឡារិករវាងបុរសម្នាក់ និងនារីម្នាក់" ហើយមាត្រា៦ចែងថាអាពាហ៍ពិពាហ៍មួយ ត្រូវបានហាមឃាត់រវាងបុគ្គលម្នាក់ដែលមានភេទដូចគ្នានឹងបុគ្គលម្នាក់ទៀត។ បើទោះបីជាមានបញ្ញត្តិច្បាប់យ៉ាងច្បាស់លាស់ក៏ដោយយ៉ាងហោចណាស់ក៏មានអាពាហ៍ពិពាហ៍នៃអ្នកដែលមានភេទដូចគ្នាបានកើតឡើងដោយមានការគាំទ្រ និង ការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋានទៀតផង។

នៅឆ្នាំ១៩៩៦ សារព័ត៌មានឌឺភ្នំពេញប៉ុស្ត៍បានរាយការណ៍អំពីអាពាហ៍ពិពាហ៍រវាងស្ត្រីពីរនាក់នៅខេត្តកណ្តាលនៅឆ្នាំ១៩៩៥។ អ្នកស្រី ខៅ សុខា ដែលបានរៀបការជាមួយដៃគូរបស់គាត់ដែលជាស្ត្រីម្នាក់ឈ្មោះ ពុំ អេត បានប្រាប់សារព័ត៌មានថា "អាជ្ញាធរគិតថានេះជារឿងចម្លែក តែពួកគេបានយល់ព្រមលើកលែងលើករណីនេះ ដោយសារខ្ញុំមានកូនបីនាក់រួចមកហើយ (ដោយសារអាពាហ៍ពិពាហ៍លើកមុន)។ ពួកគេនិយាយថា ប្រសិនបើយើងទាំងពីរនាក់នៅលីវ (មិនទាន់មានកូន) ពួកគេនឹងមិនអនុញ្ញាតឲ្យរៀបការទេ ពីព្រោះយើងមិនអាចបង្កើតកូនបាន។"[49] អាពាហ៍ពិពាហ៍នេះហាក់ដូចជាទទួលបានការយល់ព្រមជាផ្លូវការ និងត្រូវបានគេដឹងថាជាករណីមួយដែលមានការទាក់ទាញដោយមានអ្នកចូលរួមចំនួន២០០នាក់ រួមទាំងព្រះសង្ឃ និងមន្ត្រីថ្នាក់ខ្ពស់មកពីខេត្ត។[50]

មាត្រា៣៦នៃរដ្ឋធម្មនុញ្ញបានធានាអំពីសិទ្ធិការងារ ដោយមិនគិតអំពីយេនឌ័រ *"ប្រជាពលរដ្ឋទាំងពីរភេទមានសិទ្ធិជ្រើសរើសមុខរបរបរសមស្របតាមសមត្ថភាពរបស់ខ្លួនតាមសេចក្តីត្រូវការរបស់សង្គម។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។"* មាត្រា១២នៃច្បាប់ការងារឆ្នាំ១៩៩៧ក៏បានចែងថានិយោជកមិនគួរមានការរើសអើង ដោយសារតែលក្ខណៈសម្បត្តិ និងជំនឿនៃបុគ្គលម្នាក់ ដោយរួមបញ្ចូលទាំងផ្លូវភេទ។ ច្បាប់ការងាកម្ពុជាមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់អំពីការរើសអើងដែលទាក់ទងនឹងភេទឡើយ។ បុគ្គលស្រលាញ់ភេទដូចគ្នាមួយចំនួនបានកត់សម្គាល់ឃើញមានការរើសអើងនឹងពួកគេនៅកន្លែងការងារ និងពីសំណាក់និយោជករបស់ពួកគេ។[51]

មាត្រា៣១នៃរដ្ឋធម្មនុញ្ញក៏បានទទួលស្គាល់អំពីការអនុវត្តន៍ច្បាប់សិទ្ធិមនុស្សអន្តរជាតិនៅកម្ពុជា ដោយបានចែងថា *"ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំង*

---

[49] គាំ ទិវា និងម៉េង ហឿង "ដូចៗគ្នា ប៉ុន្តែរៀបការបាន" សារព័ត៌មាន ឌឺ ភ្នំពេញប៉ុស្ត៍: ឡៃហ្វ៍ ចេញផ្សាយថ្ងៃទី ២២ កញ្ញា ២០១០។ អាចរកបាននៅ http://www.phnompenhpost.com/index.php/2010092242205/LIFT/same-same-but-married.html។
[50] ដូចខាងលើ។
[51]មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និង RoCK សិក្ខាសាលាធ្វើឡើងនៅថ្ងៃទី ១៥ ឧសភា ២០១០ នៅភ្នំពេញ។

*អនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។"* សេចក្តីសម្រេចនៃក្រុមប្រឹក្សាធម្មនុញ្ញបានបញ្ជាក់អះអាងអំពីការលើកឡើងនេះ ដោយបាននិយាយនៅក្នុងសេចក្តីសម្រេចថា នៅក្នុងចំណោមច្បាប់ដែលអាចអនុវត្តបាន ចៅក្រមកាត់ក្តីគួរពិចារណាអំពីអនុសញ្ញាអន្តរជាតិដែលកម្ពុជាបានទទួលស្គាល់។[52]

## ច្បាប់អន្តរជាតិ

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌បានធានាសិទ្ធិពលរដ្ឋ នយោបាយ សង្គមកិច្ច វប្បធម៌ និងសេដ្ឋកិច្ចដល់បុគ្គលទាំងអស់ដោយមិនមានការរើសអើង។[53] មាត្រា១នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សចែងថា "មនុស្សទាំងអស់កើតមកដោយមានសេរីភាព និងភាពស្មើគ្នាក្នុងសេចក្តីថ្លៃថ្នូរ និងសិទ្ធិ" នៅពេលដែលមាត្រា២បានចែងថា "មនុស្សម្នាក់ៗមានសិទ្ធិដូចដែលបានកំនត់នៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស *ដោយគ្មានការកំនត់ជាក់លាក់ណាមួយ* រួមទាំងជាតិសាសន៍ ពណ៌សម្បុរ ភេទ និងស្ថានភាពផ្សេងទៀត។" មាត្រា២(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងមាត្រា២(២)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ក៏បានតម្រូវឲ្យរដ្ឋជាភាគីទាំងអស់ធានាថាសិទ្ធិដែលមានចែងនៅក្នុងអនុសញ្ញាទាំងនោះដោយមិនមានការកនត់ជាក់លាក់។ អាស្រ័យដូចនេះ វាច្បាស់លាស់ណាស់ថាសិទ្ធិមនុស្សអន្តរជាតិត្រូវបានអនុវត្តន៍ដោយស្មើភាពគ្នា ហើយការរើសអើងនឹងអ្នកស្រលាញ់ភេទដូចគ្នាអំពីការទទួលស្គាល់សិទ្ធិទាំងនោះគឺជាការរំលោភបំពានច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

មាត្រា៧នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា២៦នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយបានធានាអំពីភាពស្មើគ្នាចំពោះមុខច្បាប់ និងកិច្ចការពារពីការរើសអើង ដោយមាត្រា២៦ចែងថា *"មនុស្សគ្រប់រូបគឺស្មើគ្នានៅចំពោះមុខច្បាប់ និងមានសិទ្ធិទទួលបានការការពារស្មើគ្នាពីច្បាប់។ "* និងថា *"ច្បាប់គួរតែហាមឃាត់ការរើសអើង និងធានាថាមនុស្សគ្រប់គ្នាទទួលបានការការពារស្មើគ្នា និងមានប្រសិទ្ធភាពប្រឆាំងនឹងការរើសអើង ទោះហេតុផលណាក៏ដោយ "* រួមទាំងភេទ និងស្ថានភាពផ្សេងទៀត។ ហេតុដូចនេះ ច្បាប់សិទ្ធិមនុស្សអន្តរជាតិបានបង្កើតនូវករណីកិច្ចជាវិជ្ជមាននៃរដ្ឋជាភាគីទៅលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយដូចជាកម្ពុជាត្រូវធានាថាអ្នកស្រលាញ់ភេទដូចគ្នាទទួលបានការការពារយ៉ាងមានប្រសិទ្ធភាពពីការរើសអើងនៅក្នុងសង្គម។

[52] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៩២/០០៣/២០០៧ ចុះថ្ងៃទី ១០ កក្កដា ២០០៧។

[53] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សគឺជាសេចក្តីប្រកាសមួយដែលត្រូវបានអនុម័តដោយសន្និបាតអង្គការសហប្រជាតិនៅថ្ងៃទី១០ ធ្នូ ១៩៤៨។ មាត្រា៣១នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា កម្ពុជានឹងទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចដែលមានចែងនៅក្នុងសេចក្តីប្រកាសនោះ។ ប្រទេសកម្ពុជាបានឲ្យសច្ចាប័ន និងបានគោរពតាមកតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ សន្ធិសញ្ញាទាំងពីរបានចូលជាធរមាននៅកម្ពុជានៅថ្ងៃទី២៦ សីហា ១៩៩២។

គណកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដែលជាស្ថាប័នសន្ធិសញ្ញាអង្គការសហប្រជាជាតិដែលឃ្លាំមើលការគោរពតាមកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយបានបញ្ជាក់អំពីភាពពាក់ព័ន្ធនៃបញ្ញត្តិច្បាប់ខាងលើទាក់ទងនឹងអ្នកស្រលាញ់ភេទដូចគ្នាដោយបានថែងថា *ក្នុងគំនិតនេះ ការនិយាយយោងអំពី "ភេទ" នៅក្នុងមាត្រា២ វាក្យខណ្ឌទី១ និងទី២៦នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយគឺត្រូវបានគិតពិចារណាអំពីទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ។"*[54]

មាត្រា១២នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា១៧នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយបានធានាអំពីសិទ្ធិក្នុងភាពជាឯកជន *"គ្មានជនណាម្នាក់អាចទទួលរងការជ្រៀតជ្រែតដោយគ្មានហេតុផល និងខុសច្បាប់លើជីវិតឯកជនរបស់មនុស្សណាម្នាក់ឡើយ "* និង *" មនុស្សម្នាក់ៗមានសិទ្ធិទទួលបានការការពារពីការជ្រៀតជ្រែត ឬការវាយប្រហារ។"* នៅពេលពិនិត្យមើលអំពីមាត្រា១៧ *Toonen v. Australia* ដែលជាគណកម្មការសិទ្ធិមនុស្សបានថែងថា "នេះមិនអាចប្រកែកបានដែលថា សកម្មភាពរួមភេទដែលមនុស្សពេញវ័យស្ម័គ្រចិត្តដោយខ្លួនឯងត្រូវបានការពារដោយគំនិតនៃភាពជាឯកជន។"[55] ចាប់តាំងពីពេលនោះមក យន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានថ្កោលទោសការរំលោភបំពាន ដោយសារទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ រួមមានការសម្លាប់ការធ្វើទារុណកម្ម ការរំលោភ អំពើហិង្សា ការបាត់ខ្លួន និងការរើសអើងជាច្រើនរូបភាពទៀតនៃជីវិត។[56] ស្ថាប័នសន្ធិសញ្ញាអង្គការសហប្រជាជាតិបានអំពាវនាវឲ្យរដ្ឋបញ្ឈប់ការរើសអើងនៅក្នុងច្បាប់ និងគោនយោបាយ។ ការណ៍នេះបានជម្រុញឲ្យមានការផ្លាស់ប្តូរផ្នែកច្បាប់នៅប្រទេសមួយចំនួន[57] និងផ្តល់នូវគោលការណ៍ក្នុងការបកស្រាយសន្ធិសញ្ញាសិទ្ធិមនុស្សដែលមានស្រាប់។[58]

---

[54] គណកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ទស្សនៈនៃគណកម្មការសិទ្ធិមនុស្សតាមមាត្រា៥ វាក្យខណ្ឌទី៤ នៃពិធីសារជម្រើសស្តីពីកតិកសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ការទំនាក់ទំនងលេខ ៤៨៨/១៩៩២៖ *No. 488/1992: Toonen v. Australia* (CCPR/C/50/D/488/1992) ចុះថ្ងៃទី៤ មេសា ១៩៩៤ វាក្យខណ្ឌ៨.៧ ។

[55] ដូចខាងលើ វាក្យខណ្ឌទី៨.២។

[56] អង្គការលើកលែងទោសអន្តរជាតិ *អង្គការសហប្រជាជាតិ៖ សន្និបាតស្តីពីទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ។ សេចក្តីថ្លែងការណ៍អះអាង អំពីការសន្យានៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស* (AI Index: IOR ៤១/០៤៥/២០០៨) ចុះថ្ងៃទី ១២ ធ្នូ ២០០៨។

[57] ជាឧទាហរណ៍ ប្រទេសអេក្វាដ័របានកែរដ្ឋធម្មនុញ្ញដើម្បីដាក់បញ្ចូលទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ នៅក្នុងបញ្ញត្តិស្តីពីការប្រឆាំងការរើសអើង (មាត្រា ១១.២នៃរដ្ឋធម្មនុញ្ញ)។ នៅឆ្នាំ២០០០ ប្រទេសរូម៉ានីបានអនុម័តច្បាប់ប្រឆាំងការរើសអើងជាក់លាក់ (ច្បាប់ ១៣៧/២០០០) ដើម្បីការងារអ្នកដែលធ្លាប់បានជួប្រទះការរើសអើងពីមុន។ ច្បាប់ថ្មីនេះត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់នៅឆ្នាំ២០០៦ ដើម្បីផ្តល់អំណាចដល់ក្រុមប្រឹក្សាជាតិប្រឆាំងការរើសអើង ដើម្បីស៊ើបអង្កេតរាល់ការបំពានលើច្បាប់ និងរាយការណ៍ទៅសភា ដែលពួកគេជា អ្នកឯករាជ្យពីនយោបាយ។ សម្រាប់ការពិភាក្សា សូមមើល សាន់ គីរ៉ែន អេនរីគេ និងម៉ារី ខាវ៉ា សៀវភៅណែនាំការពារសម្រាប់អ្នការពារអ្នកស្រលាញ់ភេទដូចគ្នា(ប្រ៊ុយសែល ការការពារអន្តរជាតិ ២០១០) ទំព័រទី២៤ អាចរកបាននៅ http://www.protectionline.org/IMG/pdf/LGBTI_PMD_2nd_Ed_English.pdf។

[58]លើសពីនេះ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានពិចាណាលើករណីនៃការរើសអើងដោយសារមូលដ្ឋាននៃទំនោរផ្លូវភេទថាបានផ្ទុយទៅនឹងបញ្ញត្តិច្បាប់នៅ អនុសញ្ញាស្តីពីសិទ្ធិមនុស្សនៅអឺរ៉ុប ដូចជាសិទ្ធិទទួលបានជីវិតឯកជន (មាត្រា៨) បើទោះបីជាអនុសញ្ញាស្តីពីសិទ្ធិមនុស្សនៅអឺរ៉ុបនេះមិនបានបញ្ជាក់ច្បាស់លាស់អំពីទំនោរផ្លូវភេទ។ អនុសញ្ញា ស្តីពីសិទ្ធិមនុស្សនៅអឺរ៉ុបគឺជាអនុសញ្ញាថ្នាក់តំបន់។ នៅពេលដែលអនុសញ្ញានេះមិនអាចអនុវត្តបាននៅកម្ពុជា សេចក្តីសម្រេចនេះគឺជាគោលការណ៍សម្រាប់ការទទួលស្គាល់សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា។

## ដំណើរការវិវត្តន៍អន្តរជាតិដទៃទៀត

នៅខែមេសា ឆ្នាំ២០០៣ សន្ទុះខ្លាំងក្លានៃការទទួលស្គាល់អំពីសិទ្ធិមនុស្សទាក់ទងនឹងទំនោរផ្លូវភេទត្រូវបានលើកឡើងនៅក្នុងបទបង្ហាញមួយដោយប្រទេសប្រេស៊ីលទៅកាន់ក្រុមប្រឹក្សាសង្គមកិច្ច និងសេដ្ឋកិច្ចអង្គការសហប្រជាជាតិស្តីអំពីសេចក្តីព្រៀងដំណោះស្រាយសិទ្ធិមនុស្ស និងទំនោរផ្លូវភេទដើម្បីធ្វើការពិចារណាដោយគណកម្មាធិការសិទ្ធិមនុស្សនៅក្នុងកិច្ចប្រជុំលើកទី១៩។ សេចក្តីព្រៀងដំណោះស្រាយ៦ចំនុចដែលមានការគាំទ្រពីប្រទេសចំនួន១៩ បានសង្កត់ធ្ងន់ថា"លក្ខណៈជាសកលនៃសិទ្ធិមនុស្សនិងសេរីភាពគឺហួសពីការសួរសំនួរ និងថាការទទួលបានសិទ្ធិ និងសេរីភាពបែបនេះមិនគួរត្រូវបានរារាំងដោយសារហេតុផល ឬទំនោរផ្លូវភេទឡើយ។"[59] ដំណោះស្រាយនេះក៏បានស្នើសុំឲ្យរដ្ឋទាំងអស់លើកស្ទួយ និងការពារសិទ្ធិមនុស្សទាំងអស់គ្នា ដោយមិនគិតអំពីមូលដ្ឋានទំនោរផ្លូវភេទរបស់ពួកគេ។[60]

ដំណោះស្រាយនៃប្រទេសប្រេស៊ីលទទួលរងការជំទាស់យ៉ាងខ្លាំងពីរដ្ឋឥស្លាម ហើយត្រូវបានពន្យាពេលដើម្បីធ្វើការពិចារណានៅក្នុងកិច្ចប្រជុំលើកទី៦០នៃគណកម្មាធិការសិទ្ធិមនុស្សនៅឆ្នាំបន្ទាប់។ ក៏ប៉ុន្តែប្រទេសប្រស៊ីលបានសម្រេចចិត្តបោះបង់សេចក្តីសម្រេចនោះចោលនៅក្នុងកិច្ចប្រជុំលើកទី៦០ ដោយសារគេបានបង្ហាញច្បាស់ថាគេមិនអាចទទួលបានមតិឯកភាពគ្នាទេ។

នៅខែវិច្ឆិកា ឆ្នាំ២០០៦ អ្នកជំនាញផ្នែកសិទ្ធិមនុស្សមួយក្រុមបានជួបប្រជុំនៅទីក្រុងយូកយ៉ាកាតា ប្រទេសឥណ្ឌូនេស៊ី និងបានធ្វើពង្រៀងគោលការណ៍យូកយ៉ាកាតាស្តីពីការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលទាក់ទងទៅនឹងទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ (គោលការណ៍យូកយ៉ាកាតា)។[61] យោងតាមអ្នកតាក់តែងគោលការណ៍នេះ គោលការណ៍យូកយ៉ាកាតាចំនួន២៩ "បានឆ្លុះបញ្ចាំងពីស្ថានភាពបច្ចុប្បន្ននៃច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលទាក់ទងនឹងបញ្ហាទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ។"[62] គោលការណ៍យូកយ៉ាកាតាត្រូវបានបង្ហាញណែនាំនៅក្នុងការបើកបង្ហាញថ្នាក់ខ្ពស់ចំនួន២លើក។ លើកទី១នៅក្នុងកិច្ចប្រជុំនៃក្រុមប្រឹក្សាសិទ្ធិមនុស្សនៅទីក្រុងហ្សឺណែវ នៅខែមិនា ឆ្នាំ២០០៧ និងលើកទី២នៅឆ្នាំបន្ទាប់មកនៅក្នុងអង្គប្រជុំអង្គការសហប្រជាជាតិនៅទីក្រុងញ៉ូយក។[63]

---

[59] អ្នកតំណាងអចិន្ត្រៃយ៍នៃប្រទេសប្រស៊ីលប្រចាំនៅអង្គការសហប្រជាជាតិ ពង្រៀងដំណោះស្រាយស្តីពីសិទ្ធិមនុស្ស និងទំនោរផ្លូវភេទ (E/CN.៤/២០០៣/L.៩២)ចុះថ្ងៃទី១៧ មេសា ២០០៣។ អាចរកបាននៅ http://ilga.org/ilga/en/article/406។

[60] ដូចខាងលើ ។

[61] សន្និសិទ្ធិនៃអ្នកសិក្សាច្បាប់អន្តរជាតិ យូកយ៉ាកាតា ឥណ្ឌូនេស៊ី ថ្ងៃទី ៦-៩ វិច្ឆិកា ២០០៦ គោលការណ៍យូកយ៉ាកាតា ស្តីពីការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលទាក់ទងទៅនឹងទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ ចុះថ្ងៃទី ២៦ មិនា ២០០៧។ អាចរកបាននៅ http://www.yogyakartaprinciples.org/principles_en.pdf។

[62] ដូចខាងលើ សេចក្តីផ្តើម ។

[63] ដេវីដ ប្រោន *បង្កើតកន្លែងសម្រាប់ទំនោរផ្លូវភេទ និងការកំនត់យែនឌ័រនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិៈ សេចក្តីណែនាំអំពីគោលការណ៍យូកយ៉ាកាតា* Michigan Journal of International Law រដូវក្តៅ ឆ្នាំ២០១០ ៣១:៤, ទំព័រទី៨៤២។

អត្ថបទមួយនៅឆ្នាំ២០១០នៅក្នុង *Michigan Journal of International Law* បានកត់សម្គាល់អំពីឥទ្ធិពលនៃគោលការណ៍យូកយ៉ាកាតា ដោយលើកឡើងថា *"បើទោះបីជាមានភាពតឹងតែងរវាងភាពសកម្ម និងភាពត្រឹមត្រូវផ្នែកច្បាប់តឹងតែង គោលការណ៍នេះបានទទួលឥទ្ធិពលដែលមានកម្រិតខ្ពស់។ ពួកគេបានក្លាយនៅក្នុងដំណើរការនៃក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដែលបានដាក់បញ្ចូលទៅក្នុងគោលនយោបាយបរទេស និងក្នុងស្រុកនៅតាមប្រទេសមួយចំនួនត្រូវបានការកោតសរសើរ និងជជែកវែកញែកដោយស្ថាប័នសិទ្ធិមនុស្សនៅអឺរ៉ុប និងអាមេរិចខាងត្បូង និងបានធ្វើការតាមវិធីសាស្ត្ររបស់គេនៅក្នុងនៃទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអ្នករាយការណ៍សិទ្ធិមនុស្ស។"*[64]

នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០០៨ សន្និះខ្លាំងក្លានៅតែបន្ត នៅពេលប្រទេសចំនួន៣៤ដែលជាសមាជិកនៃ*អង្គការសហអាមេរិច*បានយល់ព្រមលើដំណោះស្រាយមួយស្តីពីសិទ្ធិមនុស្ស ទំនោរផ្លូវភេទ និងការកំនត់យែនឌ័រដែលបានអះអាងឡើងវិញអំពីភាពជាសកលនៃសិទ្ធិមនុស្សបង្ហាញពីកង្វល់អំពីការរំលោភបំពានសិទ្ធិមនុស្សដែលបានធ្វើឡើងប្រឆាំងនឹងបុគ្គលដោយសារទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ ព្រមទាំងបានដោះស្រាយ ដោយបានដាក់បញ្ចូលជាប្រធានបទនៅលើរបៀបវារៈនៅក្នុងគណកម្មការកិច្ចការយុត្តិធម៌ និងនយោបាយ។[65]

នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ សេចក្តីថ្លែងការណ៍មួយដែលគាំទ្រដោយប្រទេសបារាំងស្តីពីត្រូវបានបង្ហាញនៅក្នុងកិច្ចប្រជុំអង្គការសហប្រជាជាតិ និងទទួលបានការគាំទ្រពីប្រទេសចំនួន៦៦។ សេចក្តីប្រកាសបានអំពាវនាវឲ្យ "រដ្ឋទាំងអស់ និងស្ថាប័នសិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធធ្វើការប្តេជ្ញាចិត្តលើកកម្ពស់ការការពារសិទ្ធិមនុស្សទាំងអស់គ្នា ដោយមិនគិតទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ" និងជម្រុញឲ្យ "រដ្ឋចាត់វិធានការចាំបាច់ដើម្បីធានាថានៅក្នុងកាលៈទេសៈណាក៏ដោយ ទំនោរផ្លូវភេទ និងការកំនត់យែនឌ័រគឺជាមូលដ្ឋាននៃទណ្ឌកម្មព្រហ្មទណ្ឌ ជាពិសេសការធ្វើទុក្ខបុកម្នេញ ការចាប់ខ្លួន និងការឃុំខ្លួន។"[66] សេចក្តីថ្លែងការណ៍ជំទាស់នឹងសេចក្តីប្រកាសនេះត្រូវបានចុះហត្ថលេខា ដោយប្រទេសចំនួន៥៧ ដែលភាគច្រើននៅអាហ្វ្រិច និងមជ្ឈឹមបូពារ៌។ ប្រទេសកម្ពុជាមិនបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ទាំងពីរទេ។

---

[64] ដូចខាងលើ ទំព័រទី ៨២៥-៨២៦។

[65] សន្និបានអង្គការសហរដ្ឋអាមេរិច សេចក្តីសម្រេចលេខ ២៤៣៥៖ សិទ្ធិមនុស្ស ទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ (AG/RES. 2435 (XXXVIII-O/08)) ដែលត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំលើកទី៤ នៅថ្ងៃទី៣ មិថុនា ២០០៨។

[66] អ្នកតំណាងអចិន្ត្រៃយ៍ប្រចាំនៅអង្គការសហប្រជាជាតិនៃប្រទេសអាហ្សង់ទីន ប្រេស៊ីល ក្រូអាត បារាំង ហ្គាបុង ជប៉ុន ហូល្លង់ និងន័រវេសលិខិតចុះថ្ងៃទី ១៨ ធ្នូ ២០០៨ពីអ្នកតំណាងអចិន្ត្រៃយ៍ប្រចាំនៅអង្គការសហប្រជាជាតិដូចជាអាហ្សង់ទីន ប្រេស៊ីល ក្រូអាត បារាំង ហ្គាបុង ជប៉ុន ហូល្លង់ និងន័រវេសថ្លែងនៅសន្និបាត (A/63/635) ថ្ងៃទី ២២ ធ្នូ ២០០៨។

ដំណើរការវិវត្តន៍ទាំងនេះគឺជាផ្នែកមួយនៃចលនារីកធំធាត់ដែលបានទទួលស្គាល់ថាបញ្ហានៃសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នាមិនត្រឹមតែជាសិទ្ធិដែលទាក់ទងនឹងផ្លូវភេទប៉ុណ្ណោះទេ ប៉ុន្តែគឺជាសិទ្ធិមនុស្សជាសកលដោយមិនគិតអំពីផ្នែកទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ។[67]

[67] ចលនានេះមានអ្នកពាក់ព័ន្ធដូចជាគណកម្មាធិការសិទ្ធិមនុស្ស និងសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នាអន្តរជាតិ សូមមើល www.iglhrc.org។ វាក៏រួមមានសេចក្តីថ្លែងការណ៍ម៉ុងរេអាល់ ដែលត្រូវបានបង្កើតឡើងនៅក្នុងសន្និសិទ្ធអន្តរជាតិស្តីពីសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នានៅ Outgames ពិភពលោកលើកទី១ នៅថ្ងៃទី ២៩ កក្កដា ២០០៦។ សេចក្តីប្រកាសនេះកនត់ថា នៅពេលដែលពិភពលោកបានបន្តគោរពសិទ្ធិមនុស្សទាំងអស់ដោយមិនគិតពីភេទ សាសនា ជំនឿ និងពណ៌សំបុរ ការងារតិចតួចត្រូវបានគេធ្វើឡើងដើម្បីដោះស្រាយនូវការរីកចំរើននៃសិទ្ធិដោយមិនគិតអំពីទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ សូមមើល www.,declarationofmontreal.org/declaration (ដែលបានបើកមើលនៅថ្ងៃទី ១២ តុលា ២០១០)។ យុវជនស្រលាញ់ភេទដូចគ្នាស្កុតឡេនបានបង្កើតធម្មនុញ្ញនៃសិទ្ធិមួយដែលដូចគ្នា នឹងសេចក្តីថ្លែងការណ៍ម៉ុងរេអាល់ ដោយផ្អែកលើសិទ្ធិមនុសុសជាមូលដ្ឋានដែលបានកំនត់នៅក្នុងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស សូមមើល www.lgbtyouth.org/charter.htm (ដែលបានបើកមើលនៅថ្ងៃទី ១២ តុលា ២០១០)។

## ៥. ចលនាអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជា

គេឃើញមានដំណើរការវិវត្តន៍ជាវិជ្ជមាននៅកម្ពុជាដែលបញ្ជាក់ថាសហគមន៍អ្នកស្រលាញ់ភេទដូចគ្នាបានកកើតឡើង។ ការផ្លាស់ប្តូរពីសង្គ្រាមស៊ីវិល និងការឆ្ពោះទៅរកកិច្ចសហប្រតិបត្តការថ្នាក់តំបន់ និងអន្តរជាតិនៃសិទ្ធិមនុស្សបានបង្កើតឲ្យមានបរិយាកាសដែលអំណោយផលខ្លាំងជាងនេះសម្រាប់អ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជាក្នុងការទំនាក់ទំនងជាមួយសហគមន៍អ្នកស្រលាញ់ភេទដូចគ្នាទូទាំងពិភពលោក។ ក្រៅពីនេះ ការបង្កើនលទ្ធភាពប្រើប្រាស់អ៊ីនធើណេត និងការរីកសាយភាយនៃប្រធានបទនេះបានធ្វើ ឲ្យព័ត៌មានអាចរកបាន និងឱកាសក្នុងការទំនាក់ទំនង។ ប្រព័ន្ធអ៊ីនធើណេតបានធ្វើឲ្យអ្នកស្រលាញ់ភេទកម្ពុជាអាចទាក់ទងជាមួយអ្នកស្រលាញ់ភេទដូចគ្នាផ្សេងៗទៀត ដើម្បីលើកកម្ពស់ការយល់ដឹងទៅដល់សហគមន៍អ្នកស្រលាញ់ភេទដូចគ្នាទូទាំងសកលលោកមួយ និងលទ្ធភាពនៃការចូលរួម។

នៅឆ្នាំ២០០៣ សកម្មជនកម្ពុជា និងអន្តរជាតិបានចាប់ផ្តើម *កម្មវិធី 'មោទនភាព'* នៅភ្នំពេញដែលជាការប្រារព្ធឡើងប្រចាំឆ្នាំ និងការទទួលស្គាល់សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា ដោយមានសកម្មភាពដូចជាមហោស្រពភាពយន្ត សិល្បៈបង្ហាញ និងការប្រមូលផ្តុំលក្ខណៈសង្គម និងស្របពេលជាមួយទិវាអន្តរជាតិប្រឆាំងនឹងបុរសរួមភេទជាមួយបុរស។[68] នេះគឺជា*ព្រឹត្តិការណ៍មោទនភាពធំជាងគេ* នៅភ្នំពេញ នៅឆ្នាំ២០០៩ ដោយមានអ្នកចូលរួមជាង៤០០នាក់។ បន្ទាប់ពីជោគជ័យនៃព្រឹត្តិការណ៍នេះ អ្នកសម្របសម្រួលកម្មវិធីបានសម្រេចបង្កើត RoCK ។ គោលបំណងនៃក្រុមនេះគឺគាំទ្រ ពង្រឹង និងពង្រីកសហគមន៍អ្នកស្រលាញ់ភេទដូចគ្នាដែលមានស្រាប់នៅកម្ពុជា និងលើកកម្ពស់ការយល់ដឹងអំពីបញ្ហា និងសិទ្ធិនៃអ្នកស្រលាញ់ភេទដូចគ្នា។ អង្គការនេះចែកចេញជាក្រុមការងារ៤គឺ អប់រំសហគមន៍ សិទ្ធិ និងការតស៊ូមតិអ្នកស្រលាញ់ភេទដូចគ្នា ការគាំទ្រស្ត្រីស្រលាញ់ស្ត្រី និងគណកម្មការរៀបចំកម្មវិធីមោទនភាពឆ្នាំ២០១០។ ការបង្កើត RoCK បញ្ជាក់ពីការរីកលូតលាស់យ៉ាងច្បាស់លាស់សម្រាប់អ្នកស្រលាញ់ភេទនៅកម្ពុជា ដើម្បីចូលរួមយ៉ាងសកម្មក្នុងបុព្វហេតុសិទ្ធិមនុស្ស។

អង្គការ និងការផ្តួចផ្តើមដូចខាងក្រោមកំពុងចូលរួមចំណែកនៅក្នុងចលនានៃអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជា:

- RoCK គឺជាក្រុមស្ម័គ្រចិត្តមិនរកប្រាក់កំរៃដែលមានគោលបំណងគាំទ្រអ្នកស្រលាញ់ភេទដូចគ្នាតាមរយៈការទទួលស្គាល់ និងការលើកកម្ពស់ភាពចំបាច់នៃសមភាព និងការគោរព ដោយមិន

[68]សូមមើល http://phnompenhpride.blogspot.com/។

គិតអំពីទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ។[69] នៅដើមឆ្នាំ២០១០ RoCK បានបង្កើតក្រុមការងារស្តីពីសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា ដើម្បីជម្រុញ និងការពារសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា។ ក្រុមការងារនេះមានគោលបំណងជួយសង្គ្រោះអ្នកស្រលាញ់ភេទដូចគ្នាកម្ពុជាឲ្យរួចផុតពីការរើសអើង និងការរំលោភបំពានគ្រប់រូបភាព ទទួលបានការទទួលស្គាល់ពីភាពចម្រុះខាងផ្លូវភេទ និងការកំនត់យែនឌ័រ ព្រមទាំងបានដឹងពីសមភាពនៃសិទ្ធិជួបជុំគ្នាសម្រាប់មនុស្សដែលគេស្គាល់ថាជាអ្នកស្រលាញ់ភេទដូចគ្នា។

- អង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជំងឺអេដស៍ (KHANA)[70] ដែលបង្កើតឡើងដំបូងនៅឆ្នាំ១៩៩៦ និងជាគម្រោងមួយនៃអង្គការសម្ព័ន្ធភាពអន្តរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានបង្កើតប្រព័ន្ធទិន្នន័យពីការផ្តួចផ្តើមតូចៗនៅតាមមូលដ្ឋានដែលបានធ្វើការលើបញ្ហារបស់អ្នកស្រលាញ់ភេទដូចគ្នា។[71]
- មណ្ឌលសំចតមួយចំនួនអំពីបែបផែនជីវិតរបស់អ្នកស្រលាញ់ភេទដូចគ្នាក៏ត្រូវបានបង្កើតឡើងដោយអ្នកគាំទ្រ ក្នុងស្រុក និងបរទេសចំពោះសហគមន៍អ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជា។[72] បើទោះបីមានការ ប្តេជ្ញាចិត្តច្រើនបានបង្កើតឡើងសម្រាប់ក្រុមបុរសស្រលាញ់បុរសក៏ដោយ ក៏មានកិច្ចខិតខំប្រឹង ប្រែងមួយសម្រាប់ជួយស្ត្រីស្រលាញ់ស្ត្រីត្រូវបានបង្កើតឡើងផងដែរ។
- គេហទំព័រ 'Mstylekhmer'[73] កំពុងដំណើរការឆ្ពោះទៅការកសាងសហគមន៍អ្នកស្រលាញ់ភេទដូចគ្នាតាមរយៈការផ្តល់នូវការគាំទ្រផ្នែកសង្គម និងព័ត៌មានទៅដល់សហគមន៍អ្នកស្រលាញ់ភេទដូចគ្នាទាំងមូល។
- មេតា ហៅ ដែលជាបារ និងរោងភាពយន្តមួយនៅភ្នំពេញ បានបញ្ចាំងកុនពីបញ្ហានៃអ្នកស្រលាញ់ភេទដូចគ្នាជារៀងរាល់ខែ។
- *ក្លឹប MStyle* កំពុងជួយគាំទ្របុរសស្រលាញ់បុរស និងផ្តល់ឱកាសដល់អ្នកស្រលាញ់ភេទដូចគ្នាជួបពិភាក្សាគ្នាពីជីវិតផ្ទាល់ខ្លួនរបស់ពួកគេ។
- *កាហ្វេតាហ្សា* គឺហាងកាហ្វេ និងភោជនីយដ្ឋានមួយនៅភ្នំពេញទើបបើកថ្មី ដើម្បីផ្តល់នូវឱកាសច្រើនទៀតដល់អ្នកស្រលាញ់ភេទដូចគ្នា ជាពិសេសស្ត្រីស្រលាញ់ស្ត្រី ក្នុងការចែករំលែកបទពិសោធន៍របស់ពួកគេ។

អ្វីដែលជាភស្តុតាងនៅក្នុងដំណើរការវិវត្តន៍គឺថាការពិភាក្សាពីបញ្ហានៃស្ត្រីស្រលាញ់ស្ត្រីដូចគ្នា គឺនៅឃើតជាងការពិភាក្សាអំពីបុរសដែលស្រលាញ់បុរសដូចគ្នា។[74] ក្រៅពីអង្គការអ្នកស្រលាញ់ភេទដូចគ្នា

[69] សូមមើល http://phnompenhpride.blogspot.com/ សម្រាប់ព័ត៌មានបន្ថែមពីសកម្មភាពរបស់កម្មវិធីមោទនភាពរបស់ RoCK ។

[70] សូមមើល http://www.khana.org.kh/ សម្រាប់ព័ត៌មានបន្ថែម។

[71] ឧទាហរណ៍មួយគឺសេវាសុខភាពសង្គមរបស់បុរស ដែលអាចរកបាននៅ www.khana.org.kh/images/OD/Men1.htm។

[72] សូមមើល ឧទាហរណ៍ "Cambodia Out" (www.cambodiaout.com/) និង "Queer Cambodia" (www.queercambodia.blogspot.com/)។

[73] Available at: www.mstylekhmer.com

ថ្នាក់តំបន់ Utopia Asia[75] ដែលបានផ្តល់នូវធនធានពីបញ្ហាស្ត្រីស្រលាញ់ស្ត្រីដូចគ្នាជាមួយនឹងដៃគូការងារបុរសស្រលាញ់បុរស គេនៅមិនទាន់មានអង្គការស្ត្រីស្រលាញ់ស្ត្រីក្នុងស្រុកណាមួយបានដំណើរការនៅកម្ពុជានៅឡើយទេ។ នៅពេលដែល*បណ្តាញស្ត្រីសម្រាប់ការរួបរួមគ្នា* (ដែលជាអ្នកតំណាងតាមមូលដ្ឋាននៃអ្នករកស៊ីផ្លូវភេទនៅភ្នំពេញ)បានគាំទ្រសិក្ខាសាលានៃអ្នកស្រលាញ់ភេទដូចគ្នាដែលបានរៀបដំដោយ RoCK ។ គេទាមទារឲ្យមានគំនិតផ្តួចផ្តើមស្ត្រីស្រលាញ់ស្ត្រីឲ្យកាន់តែច្បាស់លាស់ថែមទៀត។

លើសពីនេះ សហគមន៍អ្នកមានភេទទីបីដែលបានចងក្រងឡើងដើម្បីធ្វើការប្រជុំរវាងអ្នករកស៊ីផ្លូវភេទជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសារព័ត៌មាន ក៏មានតំណាងតិចតួចនៅក្នុងការពិភាក្សាតិចតួចដែលបានរៀបចំឡើងនៅកម្ពុជា។ បន្ថែមពីលើនេះ បញ្ហាភេទទីបីថ្មីៗនេះត្រូវបាន បញ្ជាក់អះអាងឡើងវិញដោយអ្នកស្រី សម សុធាវី ដែលជាសកម្មជនម្នាក់ដែលមិនត្រឹមតែធ្វើការដើម្បីលើកកម្ពស់សិទ្ធិស្ត្រីរកស៊ីផ្លូវភេទប៉ុណ្ណោះទេ ថែមទាំងធ្លាប់បានរងគ្រោះនៅក្នុងរបបខ្មែរក្រហម ក្នុងនាមជាស្ត្រីមានភេទទីបី និងគឺជាអ្នកដំបូងដែលបានដាក់បណ្តឹងអំពីការរំលោភបំពានផ្នែកយេនឌ័រទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។[76]

## ទិដ្ឋភាពសង្គមនៃអ្នកស្រលាញ់ភេទដូចគ្នា

ជីវិតសង្គមរបស់អ្នកស្រលាញ់ភេទដូចគ្នានៅភ្នំពេញ និងខេត្តសៀមរាបគឺជាអ្វីដែលអាចគេពិពណ៌នាថាជាបរិយកាសសង្គមមានភាពស្និតរមួតសម្រាប់អ្នកស្រលាញ់ភេទដូចគ្នា។ នៅខណ:ដែលនេះអាចនាំប្រជាជនឲ្យជឿថាអ្នកជំនាន់ក្រោយមិនមានអារម្មណ៍ភ័យខ្លាចក្នុងការលាក់លៀមពីផ្លូវភេទរបស់ពួកគេប្រជាជនកម្ពុជាជាច្រើនអាចត្រឹមតែបានបង្ហាញនូវផ្លូវភេទរបស់ពួកគេនៅក្នុងបរិយាកាសជិតស្និតណាមួយប៉ុណ្ណោះ។ មនុស្សភាគច្រើនត្រូវមានជីវិតរស់នៅពីរ គឺមានភាពរីករាយនៅក្នុងបាររបស់បុរសដែលស្រលាញ់បុរស នៅពេលដែលត្រូវរក្សានូវរូបរាងដែលមានផ្លូវភេទផ្សេងនៅកន្លែងសាធារណ:នៃជីវិតរបស់ពួកគេ។

ខ្សែភាពយន្តកម្ពុជាដែលផ្តោតលើមនុស្សស្រលាញ់ភេទដូចគ្នាបានចាប់ផ្តើមកើតឡើង និងបានធ្វើឲ្យលេចឡើងនូវអត្តសញ្ញាណនៃអ្នកស្រលាញ់ភេទដូចក្នុងដើម្បីធ្វើការបញ្ជ្រាប។ នៅពេលដែលស្ត្រីស្រលាញ់ស្ត្រីដូចគ្នា និងបញ្ហារបស់ពួកេគមានការមើលឃើញតិចតួចនៅកម្ពុជា ខ្សែភាពយន្តខ្មែរមួយដែលទើបតែផលិតនាពេលថ្មីៗនេះមានចំណងជើង *ខ្ញុំជាអ្នកណា?* បានរៀបរាប់អំពីរឿងរ៉ាវស្នេហា

---

[74] មេហាន ឡេវីស *ស្ត្រីស្រលាញ់ស្ត្រីដូចគ្នាកម្ពុជាមិនមានព័ត៌មានសុខភាពផ្លូវភេទ។* ការចេញផ្សាយដែលគ្មានកាលបរិច្ឆេទ។ អាចរកបាននៅ http://healthdev.net/site/post.php?s=6671។

[75] សូមមើល http://www.utopia-asia.com/។

[76] អេនឌ្រូ នេត *សាលាក្តីខ្មែរក្រហមមិនបានបិទបាំងការរំលោភបំពានផ្លូវភេទ* *Inter Press Service* ចេញផ្សាយថ្ងៃទី ៨ កញ្ញា ២០០៨។

រវាងស្ត្រីពីរនាក់។[77] ដោយសារតែចំណាងជើងនៃរឿង ការបើកសម្ពោធខ្សែភាពយន្តនេះបានធ្វើឲ្យមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលបានទាក់ទាញអ្នកទស្សនាច្រើនជាង៥០០០នាក់នៅក្នុងសប្តាហ៍ដំបូងនៅតាមរោងកុន។[78]

នៅខណៈពេលដំណើរការវិវត្តន៍ដែលបានរៀបរាប់ខាងលើទទួលបានការលើកទឹកចិត្ត គេត្រូវកត់សម្គាល់ផងដែរថា ប្រជាជនកម្ពុជាភាគច្រើនដែលរស់នៅតំបន់ជនបទមិនបានដឹងពីដំណើរវិវត្តន៍នេះដែលបានកើតឡើងនៅភ្នំពេញ ឬតាមសហគមន៍លើប្រព័ន្ធអ៊ីនធើណែត។ ហេតុដូច្នេះ ការងារច្រើនទៀតត្រូវចាំបាច់ធ្វើ ហើយត្រូវប្រើប្រាស់យុទ្ធសាស្ត្រខុសៗគ្នាដើម្បីបានគ្របដណ្តប់ទៅដល់អ្នកស្រលាញ់ភេទដូចគ្នានៅតាមខេត្ត។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា តាមរយៈគម្រោងសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា សង្ឃឹមថានឹងធ្វើការរួមគ្នាជាមួយក្រុម និងអ្នកស្រលាញ់ភេទដូចគ្នាដើម្បីលើកកម្ពស់សិទ្ធិ អ្នកស្រលាញ់ភេទដូចគ្នាច្រើនថែមទៀតនៅទូទាំងប្រទេសកម្ពុជា។

[77] ខ្ញុំជាអ្នកណា?(១៩៩៩) ត្រូវបានផលិត និងដឹកនាំរឿងដោយអ្នកស្រី ពាន់ ភួងបុប្ផា។
[78] លឹម សៀងហេង *ខ្ញុំជាអ្នកណា? ធ្វើឲ្យបញ្ហាភេទដូចគ្នាមានលក្ខណៈជំហា* សារព័ត៌មាន ឌឹ ភ្នំពេញបុស្តិ៍ ចេញផ្សាយថ្ងៃទី ២៧ មេសា ២០០៩។

# ៦. សន្និដ្ឋាន

អ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជាជួបប្រទះនូវការរំលោភបំពាន និងការរើសអើងជាច្រើនរូបភាព។ ការប្រតិបត្តិរបស់សង្គមទៅលើក្រុមអ្នកស្រលាញ់ភេទដូចគ្នាមានន័យថាមនុស្សជាច្រើនត្រូវបានបង្ខំឲ្យរៀបការ និងមានកូន ដែលពួកគេអាចរស់នៅ ឬមានទំនាក់ទំនងណាមួយដែលខ្លួនឯងចង់បាន។ អ្នកដែលបានបើកជំហាថាជាអ្នកស្រលាញ់ភេទដូចគ្នាប្រឈមមុខជាមួយការមិនរាប់រកពីក្រុមគ្រួសារ និងគ្មានបណ្តាញគាំទ្រ ឬការគាំទ្រផ្នែកសេដកិច្ច ហើយតែងតែងាយរងគ្រោះថែមទៀត។ នៅពេលដែលអ្នកស្រលាញ់ភេទដូចគ្នាជួបប្រទះការរំលោភបំពាន អ្នកដែលពួកគេអាចពឹងពាក់បានមានដូចជាប៉ូលីសតែងតែមិនមានការចាប់អារម្មណ៍ ឬបានពាក់ព័ន្ធនឹងការបំពានផងដែរ។ ការណ៍ដែលថាសិទ្ធិរបស់អ្នកស្រលាញ់ភេទដូចគ្នាត្រូវបានចាត់ថ្នាក់ទាបលើក្នុងរបៀបវារៈសិទ្ធិមនុស្សបច្ចុប្បន្ននៅកម្ពុជាបានធ្វើអោយបញ្ហាកាន់តែអាក្រក់ទៅៗ។

ដោយសារកង្វះខាតព័ត៌មាន និងការគាំទ្រដែលអាចមានការចាំបាច់ត្រូវវាយតម្លៃអំពីស្ថានភាពអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជានាពេលបច្ចុប្បន្ន តាមរយៈការចងក្រងករណីរំលោភបំពាន និងការរើសអើង និងនាំឲ្យក្រុម និងអ្នកស្រលាញ់ភេទដូចគ្នាទាំងអស់បានជួបគ្នា។ ព្រមជាមួយនឹងការតស៊ូមតិដើម្បីទទួលបានការទទួលស្គាល់ និងការការពារសិទ្ធិរបស់អ្នកស្រលាញ់ភេទដូចគ្នា គេសង្ឃឹមថានឹងមានការផ្លាស់ប្តូរយៈពេលយូរអង្វែងនៃស្ថានភាពអ្នកស្រលាញ់ភេទដូចគ្នា។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ការធ្វើឲ្យមានការផ្លាស់ប្តូរគឺជាដំណើការមួយជំហានម្តងៗ។ ដំណាក់កាលទី១គឺផ្តួចផ្តើមការពិភាក្សាអំពីសិទ្ធិរបស់អ្នកស្រលាញ់ភេទដូចគ្នា និងបញ្ហាទាំងឡាយ។

គម្រោងសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នានៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានឹងនាំអោយមានការជួបប្រជុំគ្នារវាងក្រុម និងអ្នកស្រលាញ់ ភេទដូចគ្នាជួបគ្នា ព្រមទាំងផ្តល់ជាយន្តការសម្រាប់ការចងក្រងឯកសារ និងទទួលបានព័ត៌មានអំពីករណីរំលោភ បំពានដែលបានកើតឡើងនៅកម្ពុជា។ នៅខណៈពេលដែលរបាយការណ៍មិនបានផ្តល់នូវយុទ្ធសាស្ត្រ ដើម្បីធ្វើការតស៊ូមតិសម្រាប់សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា ការពិចារណាអំពីយុទ្ធសាស្ត្របែបនេះដោយផ្អែកលើការស្រាវជ្រាវនិងបទពិសោធន៍របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានឹងបង្កើតជាផ្នែកមួយនៃគម្រោងនេះក្នុងរយៈពេលបីឆ្នាំ។ តាមរយៈគម្រោងនេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានឹងព្យាយាមដើរតួសំខាន់ក្នុងការផ្តល់អំណាចដល់ក្រុម និងអ្នកស្រលាញ់ភេទដូចគ្នាក្នុងការតស៊ូមតិឲ្យស្ថានភាពសិទ្ធិមនុស្សសម្រាប់អ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជាមានភាពល្អប្រសើរ។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានឹងធ្វើការណែនាំពីបញ្ហានៃការទទួលស្គាល់សិទ្ធិមនុស្សទៅដល់សង្គម និងអ្នកស្រលាញ់ភេទដូចគ្នា និងជម្រុញឲ្យមានការពិភាក្សាអំពីបញ្ហានៃអ្នកស្រលាញ់ភេទដូចគ្នា។ មនុស្សគ្រប់គ្នាមានសិទ្ធិ និងសេរីភាពពីការរើសអើង និងមានសិទ្ធិ

ស្មើគ្នា។ អ្នកស្រលាញ់ភេទដូចគ្នាមិនមានអីខុសប្លែកទេ។ សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នាគឺជាសិទ្ធិមនុស្សសម្រាប់អ្នកស្រលាញ់ភេទដូចគ្នា។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០

# ៧. ឯកសារយោង

## ច្បាប់កម្ពុជា

ច្បាប់

រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៩៣ និងធ្វើវិសោធនកម្មឡើងវិញ)

ច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា (១ឆ្នាំ១៩៩៧)

ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ (ឆ្នាំ១៩៨៩)

សេចក្តីសម្រេច

ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧

## ច្បាប់ថ្នាក់តំបន់

សន្និបាតអង្គការសហរដ្ឋអាមេរិច *សេចក្តីសម្រេចលេខ ២៨៣៥៖ សិទ្ធិមនុស្ស ទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ* (AG/RES. 2435 (XXXVIII-O/08)) ដែលត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំលើកទី៤ នៅថ្ងៃទី៣ មិថុនា ២០០៨។

## ច្បាប់ និងលិខិតូបករណ៍អន្តរជាតិ

អនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ

សន្និបាតអង្គការសហប្រជាជាតិ *សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស* ដែលត្រូវបានអនុម័ត និងប្រកាសឲ្យប្រើប្រាស់ដោយសេចក្តីសម្រេចនៃសន្និបាត 217A (III) ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។

សន្និបាតអង្គការសហប្រជាជាតិ *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ* ដែលត្រូវបានអនុម័តដោយសេចក្តីសម្រេចនៃសន្និបាត 2200A (XXI) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦។

សន្និបាតអង្គការសហប្រជាជាតិ *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌* ដែលត្រូវបានអនុម័តដោយសេចក្តីសម្រេចនៃសន្និបាត 2200A (XXI) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦។

(A/63/635). ថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០០៨។ អាចរកបាននៅ http://daccess-dds-ny.un.org/doc/UNDOC/GEN/N08/667/99/PDF/N0866799.pdf?OpenElement។

ច្បាប់ករណី និងសេចក្តីសម្រេច

គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ *ទស្សនៈនៃគណៈកម្មការសិទ្ធិមនុស្ស តាមមាត្រា៥ វាក្យខណ្ឌទី៤ នៃពិធីសារជម្រើសស្តីពី កតិកសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ការទំនាក់ទំនងលេខ No. 488/1992: Toonen v. Australia* (CCPR/C/50/D/488/1992) ចុះថ្ងៃទី៤ មេសា ១៩៩៤។

លិខិតូបករណ៍អន្តរជាតិផ្សេងៗទៀត

សន្និសិទ្ធិអ្នកសិក្សាច្បាប់អន្តរជាតិ យូកយ៉ាកាតា ឥណ្ឌូនេស៊ី ថ្ងៃទី ៦-៩ វិច្ឆិកា ២០០៦ *គោលការណ៍យូកយ៉ាកាតា ស្តីពីការអនុវត្ត ច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលទាក់ទងទៅនឹងទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ* ចុះថ្ងៃទី ២៦ មិនា ២០០៧។ អាចរកបាននៅ http://www.yogyakartaprinciples.org/principles_en.pdf។

អ្នកតំណាងអចិន្ត្រៃយ៍ប្រចាំនៅអង្គការសហប្រជាជាតិនៃប្រទេសអាហ្សង់ទីន ប្រេស៊ីល ក្រូអាត បារាំង ហ្គាបុង ជប៉ុន ហូល្លង់ និងន័រវែស *លិខិតចុះថ្ងៃទី ១៨ ធ្នូ ២០០៨ ពីអ្នកតំណាងអចិន្ត្រៃយ៍ប្រចាំនៅអង្គការសហប្រជាជាតិដូចជាអាហ្សង់ទីន ប្រេស៊ីល ក្រូអាត បារាំង ហ្គាបុង ជប៉ុន ហូល្លង់ និងន័រវែសថ្លែងនៅសន្និបាត* (A/63/635) ថ្ងៃទី ២២ ធ្នូ ២០០៨។ អាចរកបាននៅ http://www.sxpolitics.org/wp-content/uploads/2009/03/un-document-on-sexual-orientation.pdf។

អ្នកតំណាងអចិន្ត្រៃយ៍នៃប្រទេសប្រេស៊ីលប្រចាំនៅអង្គការសហប្រជាជាតិ *សេចក្តីព្រៀងដំណោះស្រាយស្តីពីសិទ្ធិមនុស្ស និងទំនោរផ្លូវភេទ* (E/CN.4/2003/L.92)ចុះថ្ងៃទី១៧ មេសា ២០០៣។ អាចរកបាននៅ http://ilga.org/ilga/en/article/406។

## អត្ថបទលើប្រព័ន្ធអ៊ីនធើណេត

អឹស បាបារ "*ឃែនឌ័រចំរុះ៖ អត្តសញ្ញាណភេទទីបីពីប្រុសទៅស្រី និងកម្មវិធីអេដស៍នៅកម្ពុជា*" *ឃែនឌ័រ និងអភិវឌ្ឍន៍ ខួបទី១៤ លេខ ២ ខែកក្កដា ២០០៦ ទំព័រទី ២៦០។*

ប្រោន ដេវីដ "*បង្កើតកន្លែងសម្រាប់ទំនោរផ្លូវភេទ និងការកំនត់ឃែនឌ័រនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ: សេចក្តីណែនាំអំពីគោលការណ៍ យូកយ៉ាកាតា*" Michigan Journal of International Law នារដូវក្តៅ ឆ្នាំ២០១០ ៣១:៤, ទំព័រទី៨៤២។

## អត្ថបទសារព័ត៌មាន

ហ្វូលមែន ហ្សូល "*ព្រឹត្តិការណ៍មោទនភាពនៃអ្នកស្រលាញ់ភេទដូចគ្នាមានគោលបំណងលើកកម្ពស់ការយល់ដឹង*" សារព័ត៌មានឌី ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី១២ ឧសភា ២០០៩។

លឹម សៀងហេង "*ខ្ញុំជាអ្នកណា? ធ្វើឲ្យបញ្ហាភេទដូចគ្នាមានលក្ខណៈធំហ*" សារព័ត៌មាន ឌី ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី២៧ មេសា ២០០៩។

គាំ ទិវា និងម៉េង ហឿង "ដូចៗគ្នា ប៉ុន្តែរៀបការបាន" សារព័ត៌មាន ឌី ភ្នំពេញប៉ុស្តិ៍៖ ឡៃហ៍ ចេញផ្សាយថ្ងៃទី២២ កញ្ញា ២០១០។ អាចរកបាននៅ http://www.phnompenhpost.com/index.php/2010092242205/LIFT/same-same-but-married.html។

គាំ ទិវា និងម៉េង ហឿង "អាពាហ៍ពិពាហ៍ភេទដូចគ្នា៖ មិនខុសច្បាប់ទាំងស្រុងទេ" សារព័ត៌មាន ឌី ភ្នំពេញប៉ុស្តិ៍៖ ឡៃហ៍ ចេញផ្សាយថ្ងៃទី២២ កញ្ញា ២០១០។ អាចរកបាននៅ http://www.phnompenhpost.com/index.php/2010092242205/LIFT/same-same-but-married.html។

ស្តីលើស អាឡិច "មហាក្សត្រដែលមានអាយុ៨១ឆ្នាំ និងមានកូន១៤នាក់និយាយថាខ្ញុំមិនមែនបុរសស្រលាញ់បុរសទេ " សារព័ត៌មាន ដេលី តេលេក្រាហ្វ ចុះផ្សាយថ្ងៃទី២៥ កុម្ភៈ ២០០៤។ អាចរកបាននៅ http://www.telegraph.co.uk/news/worldnews/asia/cambodia/1455293/Im-not-gay-says-81-year-old-monarch-with-14-children.html។

## របាយការណ៍

បែតុន មីរ៉ា និងអ៊ីវែន ហ្គុងសាលេស ហ្វីហ្គោរ្យូ *ការកំនត់ឃែនឌ័រ និងអំពើសិង្សាលើបុរសស្រលាញ់បុរស និងអ្នកភេទទីបី៖ គោលនយោបាយអនុសាសន៍សម្រាប់សេវាកម្មថែទាំជំងឺអេដស៍* វ៉ាស៊ីនតោន ឌីស៊ី USAID ២០០៦ ។

តេអូដូរ អាំប្រូស៊ីអូ ខាតាឡា. ខា សុវណ្ណារ៉ា និង ជីរ៉ាត វ៉ាន់ មូរីក *ចេញពីស្រមោលៈ អាកប្បកិរិយារួមភេទពីបុរសទៅស្ត្រីនៅកម្ពុជា* (ភ្នំពេញៈ អង្គការខាណា/សម្ព័ន្ធអង្គការអន្តរជាតិប្រឆាំងនឹងជម្ងឺអេដស៍ ២០០៣)។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស *នៅតាមដងផ្លូវៈ ការឃុំឃាំងដោយគ្មានមូលហេតុច្បាស់ និងការរំលោភបំពានផ្សេងទៀតលើអ្នករកស៊ីផ្លូវភេទនៅកម្ពុជា*។ វ៉ាស៊ីនតោន ឌីស៊ី អង្គការឃ្លាំមើលសិទ្ធិមនុស្ស ខែកក្កដា ២០១០។

ជែនគីន ខារ៉ូល *អំពើហិង្សា និងភាពគ្រោះថ្នាក់នៃជំងឺអេដស៍ក្នុងចំណោមអ្នករកស៊ីផ្លូវភេទនៅភ្នំពេញ* កម្ពុជា។ វ៉ាស៊ីនតោន ឌីស៊ី USAID ២០០៦។ អាចរកបាននៅ http://www.hivpolicy.org/Library/HPP001702.pdf។

ខា សុវណ្ណារ៉ា និង គ្រីស វ៉ែត *បុរសដែលរួមភេទជាមួយបុរសនៅកម្ពុជាៈ ភាពងាយរងគ្រោះនៃជម្ងឺអេដស៍ ការពេបជ្រាយ និងការរើសអើង* (ភ្នំពេញ គោល នយោបាយ/ USAID ២០០៤)។

គីរ៉ែន សាន់ អេនរីគេ និងម៉ារី ខាវ៉ា *សៀវភៅណែនាំការពារសម្រាប់អ្នកការពារអ្នកស្រលាញ់ភេទដូចគ្នា* ។ ប្រ៊ុយសែល ការការពារអន្តរជាតិ ២០១០។

មីឆេ រ៉ូដូហា និង សារ៉ា ហាសី *អាកប្បកិរិយារួមភេទភេទ ជម្ងឺកាមរោគ និងមេរោគអេដស៍ក្នុងចំណោម បុរសដែលរួមភេទជាមួយបុរសនៅភ្នំពេញ កម្ពុជា ២០០០* (ភ្នំពេញៈ អង្គការសុខភាពគ្រួសារអន្តរជាតិ/ USAID ២០០២)។

ផុង តាន *កម្មវិធីបង្ការជំងឺអេដស៍ៈ ការសិក្សាអំពីការួមភេទរវាងបុរសទៅបុរសនៅកម្ពុជា* ។ ភ្នំពេញ អង្គការ UNESCO ២០០៨។ អាចរកបាននៅ http://unesdoc.unesco.org/images/0016/001630/163077E.pdf។


## ឯកសារលើប្រព័ន្ធអ៊ីនធើណេត


អង្គការលើកលែងទោសអន្តរជាតិ *អង្គការសហប្រជាជាតិៈ សន្និបាតស្តីពីទំនោរផ្លូវភេទ និងការកំនត់យែនឌ័រ។ សេចក្តីថ្លែងការណ៍អំណះអំណាង អំពីការសន្យានៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស* (AI Index: IOR 41/045/2008) ចុះថ្ងៃទី ១២ ធ្នូ ២០០៨។ អាចរកបាននៅ http://www.amnestyusa.org/document.php?id=ENGIOR410452008។

សារព័ត៌មានប៊ីប៊ីស៊ី "ព្រះមហាក្សត្រកម្ពុជាគាំទ្រអាពាហ៍ពិពាហ៍ភេទដូចគ្នា" ចេញផ្សាយថ្ងៃទី២០ កុម្ភៈ ២០០៤។ អាចរកបាននៅ http://news.bbc.co.uk/2/hi/asia-pacific/_3505915.stm។

ក្រុមប្រឹក្សាអន្តោប្រវេសន៍ និងជនភៀសខ្លួនកាណាដា *ព័ត៌មានប្រុសស្រលាញ់ប្រុស នៅអាស៊ីដោយអង្គការ Utopia ៖ គណបក្សរាជានិយម កម្ពុជាចែចង់អ្នកបោះឆ្នោតភេទទីបី*។ ចេញផ្សាយថ្ងៃទី២០ កក្កដា ២០០៣។ អាចរកបាននៅ http://www.utopia-asia.com/unews/article_2003_07_20_210927.htm។

ក្រុមប្រឹក្សាអន្តោប្រវេសន៍ និងជនភៀសខ្លួនកាណាដា ប្រទេសកម្ពុជា៖ *ការប្រព្រឹត្តិនៃការរួមភេទដូចគ្នានៅកម្ពុជា៖ ច្បាប់ទាក់ទងនឹង ការរួមភេទដូចគ្នា និង ការកើតមានអង្គការសិទ្ធិបុរសស្រលាញ់បុរសដូចគ្នា* ចេញផ្សាយថ្ងៃទី១៤ សីហា ២០០៣។ អាចរកបាននៅ http://www.unhcr.org/refworld/docid/403dd1fd4.html។

Integrated Regional Information Network (IRIN), *កម្ពុជា៖ ផ្តោតលើបុរសរួមភេទជាមួយបុរស និងការរីករាលដាលនៃជំងឺអេដស៍* ចេញផ្សាយថ្ងៃទី៣ មករា ២០០៧។ អាចរកបាននៅ http://www.irinnews.org/Report.aspx?ReportId=62964។

ឡេវីស មេហាន *ស្ត្រីស្រលាញ់ស្ត្រីកម្ពុជាមិនមានព័ត៌មានសុខភាពផ្លូវភេទ។* ការចេញផ្សាយដែលគ្មានកាលបរិច្ឆេទ។ អាចរកបាននៅ http://healthdev.net/site/post.php?s=6671។

នេត អេនគ្រូ "*សាលាក្តីខ្មែរក្រហមមិនបានបិទបាំងការរំលោភបំពានផ្លូវភេទ*" *Inter Press Service* ចេញផ្សាយថ្ងៃទី៨ កញ្ញា ២០០៨។

យេរី ត្រាំបាត់ *ពុទ្ធសាសនា និងការរួមភេទ*។ អត្ថបទលើប្រព័ន្ធអ៊ីនធើណេត ដែលគ្មានកាលបរិច្ឆេទ។ អាចរកបាននៅ http://www.enabling.org/ia/vipassana/Archive/T/Trembath/buddhismAndHomosexualityTrembath.html។

សារព័ត៌មានរ៉យទ័រ *សម្តេច ហ៊ុន សែនរងការរិះគន់ដោយសារកាត់កាលកូនស្រី* ចេញផ្សាយថ្ងៃទី៣១ តុលា ២០០៧។ អាចរកបាននៅ http://www.reuters.com/article/idUSBKK11415620071031។